- ព្រះសហាគមន៍រំលឹកចំណងមិត្តភាព ៤០០ឆ្នាំនៅកម្ពុជា <ទំព័រ៖ ១២-១៣
- មណ្ឌលលីនដាល់វាផ្តល់ការអប់រំនិងថែទាំកុមារក្រីក្រ <ទំព័រ៖ ១៤
- លោកដាម៉ូ ក្លាយជាបព្វជិតសហជីវិនព្រះយេស៊ូដំបូងនៅកម្ពុជា <ទំព័រ៖ ១៦



# អ្នកនាំសារ the messenger

កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី១៣

ខែ សីហា | ឆ្នាំ ២០២៣ | លេខទី ១៥៩

www.catholiccambodia.org/km/ www.facebook.com/RVAKHMER/ https://khmer.rvasia.org/

August, 2023 | #159




## រមណីយដ្ឋាន ប្រាសាទកោះកេរ ត្រូវបានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោក

ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២៣ ក្លាយជាទិវាប្រវត្តិសាស្រ្តដ៏សំខាន់មួយទៀតរបស់ជាតិ និងប្រជាជនកម្ពុជាទាំងមូល ដោយគណៈកម្មាធិការបេតិកភណ្ឌពិភពលោកនៃអង្គការយូណេស្កូ បានសម្រេចជាឯកច្ឆ័ន្ទចុះ «រមណីយដ្ឋានប្រាសាទកោះកេរ» ទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក។

រឿងពេញទំព័រទី ១២-១៣

# ការត្រាស់ហៅរបស់ ព្រះជាម្ចាស់ ចំពោះគ្រីស្តបរិស័ទ



គ្រីស្តបរិស័ទកាតូលិកមានផ្លូវជីវិត៣ ដើម្បីធ្វើដំណើររួមជាមួយព្រះជាម្ចាស់ក្នុងលោកីយ៍នេះ នោះគឺជម្រើសមានគ្រួសារ ជម្រើសរស់នៅលីវ និងជម្រើសជាអ្នកបួស ។

ទោះបីជាគ្រីស្តបរិស័ទម្នាក់ៗ មានជម្រើសយ៉ាងនេះក្តី ក៏យើងនៅតែរិះគិតអំពីជម្រើសទាំងនេះ ដើម្បីរស់នៅឲ្យសមស្របតាមបំណងរបស់ព្រះជាម្ចាស់ គឺស្វែងរកសុភមង្គល អំណរសប្បាយ និងសេចក្តីសង្ឃឹម។ គោលដៅរបស់គ្រីស្តបរិស័ទក្នុងពិភពលោក គឺមានតែមួយ គឺធ្វើយ៉ាងណាដើម្បីក្លាយជាសន្តបុគ្គលដែលអាចរួមរស់ជាមួយព្រះជាម្ចាស់អស់កល្បជានិច្ច។

ជីវិតមានគ្រួសារផ្ទាល់ខ្លួន ឬរៀបអាពាហ៍ពិពាហ៍ គឺជាអំណោយទានដែលប្រទានដោយព្រះជាម្ចាស់ ព្រោះព្រះអង្គបានបង្កើតមនុស្សជាតំណាងរបស់ព្រះអង្គ ឲ្យគេមានលក្ខណៈដូចព្រះជាម្ចាស់ ដោយបង្កើតគេជាបុរសនិងស្ត្រី(កណ១,២៧) ឲ្យគេចេះថែរក្សាគ្នា និងស្រឡាញ់គ្នា បង្កើតកូននិងបន្តពូជពង្សតទៅ ព្រមទាំងឲ្យគេគ្រប់គ្រងរាល់ស្នាព្រះហស្តរបស់ព្រះអង្គទាំងប៉ុន្មាននៅលើផែនដីនេះផងដែរ។ ព្រះសហគមន៍បានផ្តល់តម្លៃដល់គ្រួសារណាស់ គឺគ្រួសាររៀបបីដូចជាព្រះសហគមន៍តូចមួយរបស់ព្រះជាម្ចាស់ផ្ទាល់។ ព្រះអង្គគង់នៅជាមួយពួកគេ ហើយថែមទាំងប្រទានពរដល់គេថែមទៀតផង។ ដូច្នេះ គ្រួសារដែលមានឪពុកនិងម្តាយមានតួនាទីពិសេសសម្រាប់កូន គឺត្រូវធ្វើជាគំរូទាំងជំនឿនិងការព្រឹត្ត និងអប់រំកូនឲ្យស្គាល់មាគ៌ារបស់ព្រះជាម្ចាស់ ដើម្បីឲ្យគេទទួលបានមរតកនៃជំនឿ ស្រឡាញ់ព្រះជាម្ចាស់ និងហ៊ានបូជាជីវិតដើម្បីព្រះអង្គ។ ឪពុកម្តាយក៏មានតួនាទីបំភ្លឺ និងណែនាំកូនឲ្យបានស្គាល់ជម្រើសនៃជីវិតជាគ្រីស្តបរិស័ទនេះដែរ ហើយពិសេសជាងនេះ គឺត្រូវគាំទ្រនិងលើកទឹកចិត្តកូនៗឲ្យទៅមុខ ព្រោះបើសិនជាការត្រាស់ហៅរបស់ព្រះជាម្ចាស់លើជម្រើសណាហើយ នោះសូមជឿទុកចិត្តលើព្រះអង្គ ទ្រង់នឹងនាំកូនៗរបស់បងប្អូនឲ្យមានអំណរសប្បាយអស់មួយជីវិតរបស់គេ។ ចូរកុំខ្លាចនឹងថ្វាយកូនដ៏ជាទីស្រឡាញ់ ទោះបីមានតែមួយក្តីដូចលោកអាប្រាហាំដែលជាបព្វបុរសនៃជំនឿរបស់យើង ព្រោះព្រះជាម្ចាស់នឹងផ្តត់ផ្គង់ដល់បងប្អូនវិញយ៉ាងបរិបូរណ៍ (កណ២២,៨)។

ជីវិតរស់នៅលីវ ទោះបីការរស់នៅត្រូវពឹងលើខ្លួនឯងទាំងស្រុងលើជីវភាព ក៏ជម្រើសមួយនេះ ទទួលបានតម្លៃមួយដែរក្នុងព្រះសហគមន៍។ រស់នៅម្នាក់ឯង ជាសេរីភាពមួយដែលព្រះជាម្ចាស់ផ្តល់ឲ្យ ដើម្បីអាចនៅជិតស្និទ្ធជាមួយព្រះអង្គផង និងធ្វើអ្វីដែលចូលចិត្តផង។ ប៉ុន្តែនៅក្នុងសង្គមកម្ពុជា ការរស់នៅលីវ ភាគច្រើនគេមិនសូវជំរុញឬលើកទឹកចិត្តឡើយ ដោយសារភាពចាស់ជរានឹងនាំឲ្យបុគ្គលរូបនោះជួបរឿងអស់សង្ឃឹម និងពិបាករស់នៅ។ យ៉ាងណាមិញ ក៏នៅតែមានគ្រីស្តបរិស័ទមួយចំនួនតូចរើសយកផ្លូវមួយនេះ ដោយពឹងលើព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់ទំនុកបម្រុង និងផ្តល់កិច្ចថែរក្សាជានិច្ច (មថ៦,២៥-២៧)ហេតុនេះ កុំខ្វល់ខ្វាយដោយពោលថា «តើយើងនឹងមានអ្វីបរិភោគ មានអ្វីស្លៀកពាក់?» នោះឡើយ (មថ៦,៣១)។ ចូរក្លាហានឡើង ប្រសិនបើអ្នកបាននិងកំពុងជ្រើសរើសផ្លូវនេះ។

ជីវិតអ្នកបួស ជាផ្លូវមួយដែលព្រះសហគមន៍ស្ទើរគ្រប់ទីបត្រូវការចាំបាច់ណាស់ ដោយសារពួកគាត់ត្រូវបានជ្រើសរើសជាពិសេស ដើម្បីបម្រើព្រះកាយព្រះគ្រីស្តក្នុងព្រះសហគមន៍របស់ព្រះអង្គ។ អ្នកបួសក្នុងព្រះសហគមន៍កាតូលិកមានពីរបែប គឺជាសាសនទូត និងជាបព្វជិត-ជិតា។ ទោះជាក្រុមទាំងពីរប្រភេទនេះខុសគ្នាបន្តិចបន្តួចអំពីជីវិតរស់នៅក៏ដោយ តែគោលដៅតែមួយគឺបម្រើ។ បម្រើដោយចិត្តស្រឡាញ់ និងអស់ពីសមត្ថភាពរបស់ខ្លួន ដោយធ្វើជាគំរូ ផ្តល់សក្ខីភាពនៃជំនឿ និងបង្ហាញពីស្ថានបរមសុខនៅលើផែនដីនេះដល់មនុស្សទាំងអស់។ ជីវិតអ្នកបួស គឺរស់នៅលីវ តែមានព្រះសហគមន៍គាំទ្រលើជីវភាពរស់នៅ ហើយការរស់នៅគឺជាលក្ខណៈគ្រួសារអ្នកបួសដោយមានធម្មវិន័យក្រុមនិងប្រធានទទួលខុសត្រូវ។ អ្នកបួសទាំងអស់គឺត្រូវគោរពនូវគោលការណ៍បីសំខាន់ៗ គឺរស់នៅជាព្រហ្មចារីធម៌ រស់នៅដោយស្តាប់បង្គាប់ និងរស់នៅដោយដាក់ខ្លួនជាអ្នកក្រីក្រ។

បងប្អូនគ្រីស្តបរិស័ទ! បើទោះជាបងប្អូនជ្រើសរើសផ្លូវមួយណាក៏ដោយ សូមជឿថា ព្រះអង្គនឹងគង់នៅជាមួយបងប្អូនគ្រប់ពេលវេលា ណែនាំនិងថែរក្សាបងប្អូន សូមឲ្យតែបងប្អូនមានជំនឿគឺគ្រប់គ្រាន់។ កុំខ្លាចជ្រើសរើសផ្លូវរបស់ខ្លួនឡើយ កុំខ្លាចការត្រាស់ហៅរបស់ព្រះជាម្ចាស់ សូមអធិដ្ឋាន ស្តាប់សំឡេងរបស់ព្រះអង្គ (លក១១,១០)៕

CSC
Formation, Dailouge, Cooperation
ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក

ចាងហ្វាង : លោក លី សុវណ្ណា
សេចក្តីប្រកាសលេខ៖ លេខចុះបញ្ជី២០២២៖ ១២៧៩|២២ធត.ប្រ
ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧ មករា រាជធានីភ្នំពេញ
Contact: (855) 17 726 060
Email : csccambodia@gmail.com / Website : www.catholiccambodia.org
Email : catholicphnompenh@gmail.com / Website : www.catholicphnompenh.org
https://www.facebook.com/CatholicCambodia / https://www.facebook.com/CatholicPhnomPenh



# សិស្សរួមគ្នាធ្វើយុទ្ធនាការផ្សព្វផ្សាយ អប់រំពីបរិស្ថាន និងការគ្រប់គ្រងសំណល់

*អត្ថបទ៖ អង្គការសង្គ្រោះកុមារកម្ពុជា*



សិស្សានុសិស្សមួយក្រុមនៃសាលាបឋមសិក្សាជលសា ក្នុងឃុំកំពង់លួង ស្រុកក្រគរ ខេត្តពោធិ៍សាត់ បានដឹកនាំធ្វើយុទ្ធនាការផ្សព្វផ្សាយអប់រំស្តីពីបរិស្ថាន និងការគ្រប់គ្រងសំណល់ ដោយដង្ហែទូកជាក្បួនភ្ជាប់នូវបដាពាក្យស្លោក និងឧបករណ៍បំពងសម្លេងដែលមានសេចក្តីណែនាំពីការទុកដាក់សម្រាម ផលប៉ះពាល់ពីការចាកសំរាមពាសវាលពាសកាល ព្រមទាំងសារសំណូមពរដល់សហគមន៍ ក្នុងការបន្តរក្សាអនាម័យឱ្យបានល្អប្រសើរ។

យោងតាមគេហទំព័រហ្វេសប៊ុករបស់អង្គការសង្គ្រោះកុមារកម្ពុជា (Save the Children Cambodia) យុទ្ធនាការនេះ ធ្វើឡើងនាដើមខែសីហា ឆ្នាំ២០២៣ ក្នុងឃុំកំពង់លួង ស្រុកក្រគរ ខេត្តពោធិ៍សាត់។ យុទ្ធនាការនេះ មានការចូលរួមពីអាណាព្យាបាលសិស្ស គណៈកម្មការគ្រប់គ្រងសាលា ប្រជាសហគមន៍ និងអាជ្ញាធរមូលដ្ឋាន ដែលមកពីមន្ទីរអប់រំ យុវជន និងកីឡាខេត្ត គណៈអភិបាលស្រុក និងឃុំ សរុប៣៧នាក់។

កុមារា វេហា អាយុ ១១ឆ្នាំ ដែលចូលរួមដឹកនាំយុទ្ធនាការនេះ បានលើកឡើងពីទម្លាប់ប្រចាំថ្ងៃរបស់សិស្សានុសិស្សនៃសាលានេះ គឺការប្រមូលសំរាមតាមផ្លូវ និងលើទឹក ក៏ដូចជាការប្រមូលដបទឹកចាស់ដើម្បីកែច្នៃប្រើប្រាស់ជាឧបករណ៍ទាក់សម្រាម និងដាំដុះកូនរុក្ខជាតិ។

កុមារា វេហា បាននិយាយថា ៖ «ខ្ញុំ ចូលចិត្តប្រមូលសំរាម ព្រោះខ្ញុំមិនចង់ឱ្យមានសំរាមលើបឹងទន្លេសាប។ ទឹកកខ្វក់ បានធ្វើឱ្យពួកយើងឈឺ មិនអាចទៅរៀនបានជាប់លាប់។ ខ្ញុំសង្ឃឹមថា សហគមន៍របស់ខ្ញុំ នឹងឈប់ចោលសំរាម ហើយទុកដាក់សំរាមឱ្យបានត្រឹមត្រូវ»។

ជាមួយគ្នានោះដែរ អនុប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តពោធិ៍សាត់ លោក លឹម វុទ្ធី បានថ្លែងបញ្ជាក់ផងដែរពីកិច្ចសហការរបស់អង្គការ Save the Children និងការគាំទ្ររបស់គម្រោង ក្នុងការផ្តល់វគ្គបណ្តុះបណ្តាលទាក់ទងនឹងបរិស្ថានដល់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស ក៏ដូចជាលើកទឹកចិត្ត និងជំរុញឱ្យកុមារដើរតួនាទីសំខាន់ក្នុងការផ្លាស់ប្រែសហគមន៍។

លោកថា ៖ «ពួកគេ (សិស្សានុសិស្ស) បានធ្វើជាគម្រូនៅសាលារៀន និងក្នុងសហគមន៍តាមរយៈយុទ្ធនាការផ្សព្វផ្សាយ ការទុកដាក់សម្រាមឱ្យត្រឹមត្រូវ និងការចូលរួមសម្អាតសាលារៀន និងទីសាធារណៈ»។

អភិបាលរងស្រុកក្រគរ អ្នកស្រី មិត្ត សុភាព ក៏បានឡើងពីសារៈសំខាន់នៃបរិស្ថានស្អាត ក៏ដូចជាផលប៉ះពាល់ពីទឹកកខ្វក់ កើតឡើងចំពោះប្រជាសហគមន៍ ពិសេសកុមារ ដោយបានស្នើឱ្យភាគីពាក់ព័ន្ធ ចូលរួមក្នុងកិច្ចការងារនេះ។



អ្នកស្រីថា៖ «ខ្ញុំនឹងបន្តសហការ ផ្សព្វផ្សាយពីការថែទាំបរិស្ថាន ឱ្យជ្រាបទៅកាន់គ្រួសារប្រជាពលរដ្ឋនីមួយៗ អំពីការទុកដាក់កាកសំណល់ ដើម្បីឱ្យសហគមន៍នេះ គ្មានសម្រាម»។

សាលាបឋមសិក្សាជលសា គឺជាសាលាគោលដៅមួយ ដែលទទួលបានការគាំទ្រពីគម្រោង «បង្កើតបរិស្ថានដែលមានភាពស៊ាំ និងលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមនៅតំបន់ភាគខាងកើតបឹងទន្លេសាប» ក្រោមមូលនិធិគាំទ្រពីសហភាពអឺរ៉ុប គម្រោងអប់រំបរិស្ថានសម្រាប់កុមារជំនាន់ថ្មី និងគម្រោង Biobar (របាប្រមូលសម្រាម) របស់អង្គការ Save the Children។

ក្រៅពីយុទ្ធនាការផ្សព្វផ្សាយ ក្រុមការងារគម្រោងរបស់អង្គការ Save the Children ក៏បានសហការជាមួយគណៈកម្មការសាលារៀន ធ្វើឧបករណ៍ស្ទាក់សម្រាម និងបានតម្លើងនៅលើប្រឡាយមួយក្នុងតំបន់នោះ៕

# ខេត្តកែប ជាខេត្តគោលដៅទី៦ ដែលសម្រេចបានជាខេត្ត ODF

*អត្ថបទ៖ អមរិន្ទ ដានុត*

ខេត្តកែប ជាខេត្តគោលដៅទី៦ដែលសម្រេចបានជាខេត្តបញ្ចប់ការបន្ទោបង់ពាសវាលពាសកាល (ODF) និងបានប្រកាសទទួលស្គាល់ខេត្តODF ស្របតាមគោលដៅដែលបានកំណត់ដែលក្នុងនោះមាន ខេត្តស្វាយរៀង ខេត្តព្រៃវែង ខេត្តកណ្តាល ខេត្តកំពង់ស្ពឺ និងខេត្តកំពង់ឆ្នាំង។

នេះជាការថ្លែងឡើងរបស់លោក អ៊ុក រ៉ាប៊ុន អតីតរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ក្នុងពិធីប្រកាសទទួលស្គាល់ ខេត្តកែបជាខេត្តបញ្ចប់ការបន្ទោបង់ពាសវាលពាសកាល(ODF) កាលពីថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៣កន្លងមក។

លោកបានលើកឡើងដោយកោតសរសើរចំពោះការតាំងចិត្ត និងការខិតខំប្រឹងប្រែងរបស់រដ្ឋបាលខេត្តក្នុងការជម្រុញឱ្យខេត្តកែបទទួលបានជោគជ័យជាខេត្ត ODF ទី៦ នៅកម្ពុជា ហើយលោកក៏សង្ឃឹមយ៉ាងមុតមាំដែរថា រដ្ឋបាលខេត្ត និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ នៅតែបន្តការចូលរួម និងជម្រុញការងារផ្គត់ផ្គង់ទឹក និងអនាម័យជនបទ ជាពិសេសគឺការរិះរកយន្តការរក្សានិរន្តរភាពខេត្ត ODF ។

លោកមានប្រសាសន៍ថា ៖ «ការផ្គត់ផ្គង់ទឹកស្អាត អនាម័យ និងវិធីបង្ការរោគ ពិតជាមានសារៈសំខាន់ ដែលបានចូលរួមចំណែកលើកកម្ពស់លក្ខខណ្ឌរស់នៅរបស់សហគមន៍នៅជនបទឱ្យកាន់តែប្រសើរឡើង។ ខ្ញុំសូមបញ្ជាក់ថា ទឹកស្អាត គឺជាទឹកដែលថ្លា គ្មានក្លិន គ្មានពណ៌ គ្មានរសជាតិ គ្មានមេរោគ និងគ្មានសារធាតុគីមីលើសកំណត់ ហើយមិនប៉ះពាល់ដល់សុខភាព»។

ដោយឡែកអនាម័យ សំដៅទៅលើភាពស្អាត និងមានអនាម័យនៃកន្លែងរស់នៅ សហគមន៍ដែលមិនបង្កឱ្យមានផលប៉ះពាល់ដល់សុខភាព ដែលពាក់ព័ន្ធនឹងការប្រើប្រាស់ទឹក និងការគ្រប់គ្រងទុកដាក់លាមកមនុស្ស លាមកសត្វ និងសំណល់សំរាមកខ្វក់។

រីឯវិធីបង្ការរោគ សំដៅលើលក្ខណៈ និងការអនុវត្តនានាដែលជួយថែរក្សាសុខភាព និងបង្ការការរីករាលដាលជំងឺឆ្លងរួមទាំងការលាងសម្អាតដៃ ការគ្រប់គ្រងអនាម័យពេលមានរដូវ និងអនាម័យចំណីអាហារ ដែលនិយាយជារួមគឺហូបស្អាត ផឹកស្អាត និងរស់នៅស្អាត។

លោក អ៊ុក រ៉ាប៊ុនថា ៖ «រាជរដ្ឋាភិបាលតែងតែយកចិត្តទុកដាក់យ៉ាងខ្លាំងផងដែរលើការងារលើកកម្ពស់អនាម័យតាមទីសាធារណៈ ដូចជានៅតាមមន្ទីរពេទ្យ តាមសាលាឃុំ សាលាស្រុក តាមសាលារៀន និងជាពិសេសបង្គន់អនាម័យតាមស្ថានីយ៍ប្រេងឥន្ទនៈនានា ដែលមានលក្ខណៈទំនើប និងប្រកបដោយផាសុកភាព ដែលពីមុនកន្លែងទាំងអស់នេះនៅមិនទាន់មានបង្គន់អនាម័យដែលស្អាត និងមិនទាន់ទំនើបនៅឡើយ»។

លោក សោម ពិសិដ្ឋ អភិបាលខេត្តកែប បានថ្លែងថា អត្រាភាពក្រីក្ររបស់ប្រជាពលរដ្ឋនៅក្នុងខេត្តកែប ត្រូវបានកាត់បន្ថយ ពីអត្រា ១២,៨៤% នៅឆ្នាំ២០១៧ មកត្រឹម ២,៤១% នៅឆ្នាំ២០២៣នេះ។

លោកថា ៖ «យើងបានរៀបចំពិធីអបអរសាទរខេត្តកែបទទួលបានជ័យលាភី ជាខេត្តបញ្ចប់ការបន្ទោបង់ពាសវាលពាសកាល (ODF)»។

ជាមួយគ្នានេះពាក់ព័ន្ធនឹងការងារផ្គត់ផ្គង់ទឹកស្អាត សុខភាព និងអនាម័យជនបទនៅក្នុងខេត្តកែប កន្លងមកសម្រេចបានសមិទ្ធផលមួយចំនួនគួរគត់សម្គាល់ក្នុងនោះ រួមមាន៖ ការងារផ្គត់ផ្គង់ទឹកជនបទ សម្រេចបាន អណ្តូងស្នប់សរុប ចំនួន ៧៣៥អណ្តូង,អណ្តូងលូសរុបចំនួន ៧៨៦អណ្តូង ស្រះសហគមន៍ ចំនួន ១៥០ស្រះ, ពាងយក្ស ចំនួន ១.០០២ពាង, ប្រព័ន្ធចែកចាយទឹកស្អាតខ្នាតតូចសហគមន៍ ចំនួន ២កន្លែងប្រព័ន្ធចែកចាយទឹកឯកជនចំនួន២ក្រុមហ៊ុន។

សម្រាប់ការងារលើកកម្ពស់អនាម័យជនបទ លោក សោម ពិសិដ្ឋ បានលើកឡើងថា ខ្នងផ្ទះសរុបក្នុងខេត្តមាន ចំនួន ៩.២៧៥ខ្នង (ទិន្នន័យនៃការធ្វើផែនទីអនាម័យខ្នងផ្ទះ ចុងឆ្នាំ២០២២), ខ្នងផ្ទះមានបង្គន់អនាម័យប្រើប្រាស់ផ្ទាល់ខ្លួន ៨.៨៤៨ខ្នង ស្មើនឹង ៩៦,៧៨%, ខ្នងផ្ទះប្រើប្រាស់បង្គន់អនាម័យរួម ២៩៤ខ្នង ស្មើនឹង ៣,២២% ខ្នងផ្ទះចំណាកស្រុក ១៣៣ខ្នង៕

# គ្រប់គណបក្សនយោបាយអាចស្នើសុំចូលរួមជាសមាជិកឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់បាន

*អត្ថបទ៖ អមរិន្ទ ដានុត*



ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃកម្ពុជា បានចេញព្រះរាជក្រឹត្យស្តីពី «ការរៀបចំ និងការបព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់» ដែលព្រះរាជក្រឹត្យនេះមានគោលដៅបង្កើត និងកំណត់ពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សា ប្រមូលធាតុចូលនៃទស្សនៈពហុគំនិតជាប្រយោជន៍ដល់ការស្ថាបនាជាតិ។

យោងតាមព្រះរាជក្រឹត្យដែលចុះព្រះហស្តលេខាដោយព្រះមហាក្សត្រ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២៣ ដែលឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ ត្រូវមានសមាសភាពពីគណបក្សនយោបាយ ទាំងឡាយដែលបានចូលរួមក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ នៃរដ្ឋសភា ព្រមទាំងគណបក្សនយោបាយផ្សេងទៀតដែលបានចុះបញ្ជីត្រឹមត្រូវស្របតាមច្បាប់ជាធរមាន នៃព្រះរាជាណាចក្រកម្ពុជា។

ព្រះរាជក្រឹត្យស្តីការរៀបចំ និងការបព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់នេះមាន៧ជំពូក និង២១ មាត្រា ដែលបានចេញផ្សាយនាពីថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២៣ ។

គណបក្សនយោបាយដែលបានចូលរួមក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ នៃ រដ្ឋសភា ទទួលបានបុព្វសិទ្ធិជាគណបក្សស្ថាបនិកនៃឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ សម្រាប់នីតិកាល ទី៧ នៃរដ្ឋសភានេះ ក្នុងលក្ខខណ្ឌដែលគណបក្សនយោបាយនោះបានដាក់ពាក្យស្នើសុំជាផ្លូវការក្នុងរយៈពេល២សប្តាហ៍ បន្ទាប់ពីការចូលជាធរមាននៃព្រះរាជក្រឹត្យនេះ និងទទួលបានការសម្រេចយល់ព្រមពីនាយករដ្ឋមន្ត្រី សម្រាប់ការតែងតាំងជាសមាសភាពដំបូងនៃឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ ដោយអនុលោមតាមព្រះរាជក្រឹត្យនេះ។


យុទ្ធសាស្ត្របញ្ចកោណ
(ដំណាក់កាលទី១)
របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា

I-បាវចនា ទាំង៥៖ (១)កំណើន (២)ការងារ (៣)សមធម៌ (៤)ប្រសិទ្ធភាព និង(៥)ចីរភាព។
II-អាទិភាពគន្លឹះ ទាំង៥៖ (១)មនុស្ស (២)ផ្លូវ (៣)ទឹក (៤)ភ្លើង និង(៥)បច្ចេកវិទ្យា។
III-គោលដៅយុទ្ធសាស្ត្រ ទាំង៥៖
(១) ធានាឱ្យបានកំណើនសេដ្ឋកិច្ច ក្នុងអត្រាមធ្យមប្រចាំឆ្នាំ ក្នុងរង្វង់៧% ប្រកបដោយភាពធន់នឹងវិបត្តិនានា។
(២) បង្កើតការងារឱ្យបានកាន់តែច្រើន ទាំងបរិមាណនិងគុណភាព ជូនដល់ប្រជាជនកម្ពុជា ជាពិសេសយុវជន។
(៣) សម្រេចឱ្យបាននូវគោលដៅកាត់បន្ថយភាពក្រីក្រ ក្នុងអត្រាទាបជាង១០% និង បន្តខិតខំទាញទម្លាក់អត្រានៃភាពក្រីក្រឱ្យស្ថិតនៅក្នុងកម្រិតជាអប្បបរមា។
(៤) បន្តពង្រឹងសមត្ថភាពអភិបាលកិច្ច និង លើកកម្ពស់គុណភាពស្ថាប័ន ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។
(៥) ធានាចីរភាពនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និង កសាងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ។
IV-ស្នូលនៃយុទ្ធសាស្ត្រគឺ ការកែទម្រង់ និង ការពង្រឹងអភិបាលកិច្ច, ដោយមានមុំ ចំនួន៥៖
(១) ការពង្រឹង និង ការកែទម្រង់ស្ថាប័ន។
(២) ការលើកកម្ពស់សមត្ថភាពធនធានមនុស្ស និង ការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តការងារ។
(៣) ការលើកកម្ពស់ និង ការពង្រឹងភាពស្អាតស្អំនៅក្នុងរដ្ឋបាលសាធារណៈ។
(៤) ការលើកកម្ពស់ និង ការពង្រឹងប្រសិទ្ធភាពនៃច្បាប់និងប្រព័ន្ធយុត្តិធម៌។
(៥) ការពង្រឹងអភិបាលកិច្ចវិស័យឯកជន និង ធុរកិច្ច។ និងមានបរិស្ថានគ្របដណ្តប់មុំទាំង៥៖
(១) ការបន្តពង្រឹងសន្តិភាព ស្ថិរភាពនយោបាយ និង សន្តិសុខនិងសណ្តាប់ធ្នាប់សាធារណៈ។
(២) ការប្រកាន់ខ្ជាប់នូវនយោបាយការបរទេសឯករាជ្យ ដោយផ្អែកលើច្បាប់ និង ឈ្លាសវៃ។
(៣) ការធានាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ។
(៤) ការបន្តកសាងភាពជាដៃគូប្រកបដោយបរិយាបន្ន និង ស័ក្តិសិទ្ធភាព នៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍។
(៥) ការបន្តធ្វើសមាហរណកម្មស៊ីជម្រៅទៅក្នុងតំបន់ និង សាកលលោក។
V-បញ្ចកោណ ទាំង៥៖
(១) ការអភិវឌ្ឍមូលធនមនុស្ស។
(២) ការធ្វើពិពិធកម្មសេដ្ឋកិច្ច និង ការបង្កើនភាពប្រកួតប្រជែង។
(៣) ការអភិវឌ្ឍវិស័យឯកជន និង ការងារ។
(៤) ការអភិវឌ្ឍប្រកបដោយភាពធន់ ចីរភាព និង បរិយាបន្ន។
(៥) ការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមឌីជីថល។

ព្រះរាជក្រឹត្យបានបញ្ជាក់ថា ៖ «គណបក្សនយោបាយផ្សេងទៀត ទាំងគណបក្សនយោបាយដែលបានចូលរួមក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ នៃរដ្ឋសភា ទាំងគណបក្សនយោបាយដែលមិនបានចូលរួមក្នុងការបោះឆ្នោតនេះ ប៉ុន្តែបានចុះបញ្ជីត្រឹមត្រូវស្របតាម ច្បាប់ស្តីពីគណបក្សនយោបាយ អាចស្នើសុំចូលរួមជាសមាជិកឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់បាន ដោយត្រូវដាក់ពាក្យស្នើសុំជាផ្លូវការ និងត្រូវមានការសម្រេចយល់ព្រមពីនាយករដ្ឋមន្ត្រី»។

ឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ ជាយន្តការពិគ្រោះនិងផ្តល់យោបល់របស់គណបក្សនយោបាយជូនរាជរដ្ឋាភិបាល ក្រៅក្របខណ្ឌសភា ក្នុងគោលដៅលើកស្ទួយប្រសិទ្ធភាពការងារ ដើម្បីជា ប្រយោជន៍ដល់ការបម្រើសេវាជូនប្រជាជន និងការអភិវឌ្ឍសង្គមជាតិ ប្រកបដោយសក្តានុពល។ ឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់មានអាណត្តិដូចអាណត្តិរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា។

ប្រតិភូគណបក្សស្ថាបនិកនៃឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ មានសមាសភាពចំនួនបីរូប ដែលក្នុងនោះមួយរូបជាប្រធានប្រតិភូ មានឋានៈស្មើទេសរដ្ឋមន្ត្រី មួយរូបជាអនុប្រធានប្រតិភូ មានឋានៈស្មើ រដ្ឋមន្ត្រី និងមួយរូបទៀតជាសមាជិកប្រតិភូ មានឋានៈស្មើរដ្ឋលេខាធិការ។

ក្រៅពីគណបក្សស្ថាបនិក ប្រតិភូគណបក្សនយោបាយផ្សេងទៀតដែលជាសមាជិកនៃឧត្តមក្រុមប្រឹក្សា ពិគ្រោះនិងផ្តល់យោបល់ មានសមាសភាពចំនួនពីររូប ដែលក្នុងនោះមួយរូបជាប្រធានប្រតិភូ មានឋានៈស្មើ ទេសរដ្ឋមន្ត្រី និងមួយរូបទៀតជាអនុប្រធានប្រតិភូ មានឋានៈស្មើរដ្ឋមន្ត្រី។

ឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ ជួបប្រជុំពិគ្រោះ និងផ្លាស់ប្តូរយោបល់រៀងរាល់មួយខែម្តង តាមការកោះប្រជុំរបស់ប្រធានឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់។

ប្រធានឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ត្រូវជ្រើសចេញពីប្រធានប្រតិភូគណបក្សនយោបាយដោយត្រូវអនុវត្តតាមគោលការណ៍ប្តូរវេនរៀងរាល់មួយខែម្តង ដោយយកតាមលំដាប់លេខរៀងគណបក្ស នយោបាយនៅក្នុងសន្លឹកឆ្នោតដែលរៀបចំដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សម្រាប់គណបក្សស្ថាបនិក និងលំដាប់លេខរៀងជាបន្តបន្ទាប់ តាមកាលបរិច្ឆេទនៃការសម្រេចយល់ព្រមរបស់នាយករដ្ឋមន្ត្រី ចំពោះគណបក្សនយោបាយផ្សេងទៀតដែលមិនមែនជាគណបក្សស្ថាបនិក។

អគ្គលេខាធិការនៃរាជបណ្ឌិត្យសភាកម្ពុជា លោក យង់ ពៅ ថា ការបង្កើតឱ្យមានស្ថាប័ននេះគ្រាន់តែចង់បង្ហាញឱ្យមានការចូលរួមពហុមតិក្នុងសង្គមប្រជាធិបតេយ្យ ហើយការបង្កើតឱ្យមានឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់នេះក្នុងអាណត្តិទី ៧ នេះ មិនខុសពីអាណត្តិទី ៦នោះទេ។

លោកបានលើកឡើងថា ៖ «ឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់នេះ គ្រាន់តែជាជំនួយស្មារតី ត្រួតពិនិត្យ ផ្តល់យោបល់ និងពិគ្រោះយោបល់ប៉ុណ្ណោះ មិនមានឥទ្ធិពលខ្លាំងលើរដ្ឋាភិបាលនោះទេ។ រីឯការដេញដោលផ្សេងៗ គឺជាអំណាចសភា រីឯកឧត្តមក្រុមប្រឹក្សាពិគ្រោះយោបល់នេះ មិនអំណាចដូចសភាឡើយ»៕





# កម្ពុជា-អាមេរិក រួមគ្នាអភិរក្ស និងជួសជុលបេតិកភណ្ឌវប្បធម៌ដ៏សម្បូរបែបរបស់កម្ពុជា

*អត្ថបទ៖ អមរិន្ទ ដានុត*



ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងស្ថានទូតអាមេរិកនៅភ្នំពេញ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងលើកទី៥ ស្តីពីកិច្ចសហប្រតិបត្តិការផ្នែកវប្បធម៌ រវាងកម្ពុជា និងសហរដ្ឋអាមេរិក កាលពីថ្ងៃទី៣០ ខែសីហា ដែលជាការបញ្ជាក់ជាថ្មី នូវការប្តេជ្ញាចិត្តយូរអង្វែងរបស់សហរដ្ឋអាមេរិក ក្នុងការអភិរក្ស និងជួសជុលបេតិកភណ្ឌវប្បធម៌ដ៏សម្បូរបែបរបស់កម្ពុជា។

កម្ពុជា គឺជាប្រទេសតែមួយ គត់នៅតំបន់អាស៊ីអាគ្នេយ៍ ដែលមានកិច្ចព្រមព្រៀងប្រភេទនេះ។ អនុស្សរណៈនៃការយោគយល់គ្នាជាលើកដំបូង ត្រូវបានចុះហត្ថលេខានៅឆ្នាំ២០០៣ ។

យោងតាមសេចក្តីប្រកាសព័ត៌មានរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈបានឱ្យដឹងថា ការបន្តអនុស្សរណៈនៃការយោគយល់គ្នារយៈពេល៥ឆ្នាំទៀតនេះរវាងព្រះរាជាណាចក្រកម្ពុជា និងសហរដ្ឋអាមេរិកទាក់ទងនឹង «ការដាក់កម្រិតហាមប្រាមនូវការនាំចូលប្រភេទវត្ថុបុរាណ និងវត្ថុជាតិពន្ធវិទ្យានៃប្រទេសកម្ពុជា» និងកាត់បន្ថយការលួចប្លន់នៃវត្ថុបុរាណដ៏ល្អឯកពីប្រទេសកម្ពុជា។

ក្នុងរយៈពេល២០ឆ្នាំកន្លងមក អនុស្សរណៈនៃការយោគយល់គ្នា នេះបានជួយសម្រួលដល់ការបញ្ជូនត្រឡប់មកកម្ពុជាវិញនូវវត្ថុបុរាណដ៏មានតម្លៃចំនួនជាង១០០ដុំ និងបានកសាងសមត្ថភាពរបស់ជនជាតិខ្មែរដែលធ្វើការងារថែរក្សា គាំពារបេតិកភណ្ឌវប្បធម៌។

នាពិធីនោះ លោក W. Patrick Murphy ឯកអគ្គរដ្ឋទូតអាមេរិក ក៏បានប្រកាសផងដែរនូវជំនួយថវិកាចំនួន ៤៥ ម៉ឺនដុល្លា របស់ក្រសួងការបរទេសសហរដ្ឋអាមេរិក តាមរយៈមូលនិធិឯកអគ្គរដ្ឋទូតសម្រាប់ការអភិរក្សវប្បធម៌ជូនដល់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សម្រាប់បន្តការងារអភិរក្សនៅប្រាសាទភ្នំបាខែង។

> វត្ថុសិល្បៈច្រើនរាប់មិនអស់រួមមាន វត្ថុបុរាណខ្មែរនានា រូបបដិមា គ្រឿងលម្អស្ថាបត្យកម្ម និងវត្ថុសិល្បៈជាប្រភេទកុលាលភាជន៍ និងធ្វើពីសំរិទ្ធ ត្រូវបានគេលក់ និងនៅបន្តដាក់លក់ដោយខុសច្បាប់នៅលើទីផ្សារវត្ថុ សិល្បៈអន្តរជាតិ វិធានការប្រកបដោយប្រសិទ្ធភាពដើម្បីទប់ស្កាត់ការជួញដូរខុសច្បាប់នូវវត្ថុបុរាណ និងសម្បត្តិវប្បធម៌ គឺអាស្រ័យលើកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធរវាងភាគីពាក់ព័ន្ធសំខាន់

លោក W. Patrick Murphy បានមានប្រសាសន៍ថា ៖ «ប្រទេសយើងទាំងពីរមើលឃើញពីអំណាចនៃវប្បធម៌ ក្នុងការធ្វើឲ្យមនុស្សមានការរួបរួមគ្នា។ រដ្ឋអាមេរិកមានមោទនភាពចំពោះការរួមចំណែករបស់ខ្លួន ក្នុងការជួសជុល និងអភិវឌ្ឍបេតិកភណ្ឌវប្បធម៌កម្ពុជា សម្រាប់មនុស្សជំនាន់ក្រោយៗទៀត» ។








ចំណែកលោកស្រី ភឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក៏បានលើកឡើងដែរថា អស់រយៈពេលជាច្រើន ទសវត្សរ៍មកហើយ ដែលវត្ថុបុរាណរបស់កម្ពុជា ត្រូវបានលួច និងទទួលទិញដោយ អ្នកធ្វើសមុច្ច័យជាលក្ខណៈឯកជន និងបណ្ណាសារមន្ទីរនៅទូទាំងពិភពលោក»។

លោកស្រីមានប្រសាសន៍ថា ៖ «វត្ថុសិល្បៈច្រើនរាប់មិនអស់រួមមាន វត្ថុបុរាណខ្មែរនានា រូបបដិមា គ្រឿងលម្អស្ថាបត្យកម្ម និងវត្ថុសិល្បៈជាប្រភេទ កុលាលភាជន៍ និងធ្វើពីសំរិទ្ធ ត្រូវបានគេលក់ និងនៅបន្តដាក់លក់ដោយខុសច្បាប់នៅលើទីផ្សារវត្ថុ សិល្បៈអន្តរជាតិ វិធានការប្រកបដោយប្រសិទ្ធភាពដើម្បីទប់ស្កាត់ការជួញដូរខុសច្បាប់នូវវត្ថុបុរាណ និងសម្បត្តិវប្បធម៌ គឺអាស្រ័យលើកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធរវាងភាគីពាក់ព័ន្ធសំខាន់»។

តាំងពីឆ្នាំ ២០០១មក សហរដ្ឋអាមេរិក បានផ្តល់ជំនួយជាថវិកាជិត ៦លានដុល្លារ សម្រាប់ការអភិរក្ស វប្បធម៌នៅកម្ពុជា ដែលរួមមានជំនួយជាថវិកា សម្រាប់ជួសជុលប្រាសាទភ្នំបាខែង និងប្រាសាទ ជួយដល់សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង បង្កើតបញ្ជីសារពើភណ្ឌតាមប្រព័ន្ធអនឡាញនៃវត្ថុសិល្បៈនៅសារមន្ទីរតាមខេត្តនានា ការពារបេតិកភណ្ឌវប្បធម៌៕

យោងតាមស្ថានទូតអាមេរិក បានលើកឡើងដែរថា កម្ពុជា គឺជាប្រទេសតែមួយគត់នៅតំបន់អាស៊ីអាគ្នេយ៍ ដែលមានកិច្ចព្រមព្រៀងនេះ ដែលអនុស្សរណៈនៃការយោគយល់គ្នា (MOU) ជាលើកដំបូង ត្រូវបានចុះហត្ថលេខានៅឆ្នាំ ២០០៣ ។

ការបន្ត MOU ទៀតនេះ រវាងសហរដ្ឋអាមេរិក និងព្រះរាជាណាចក្រកម្ពុជា ទាក់ទងនឹង «ការដាក់កម្រិតហាមប្រាមនូវការនាំចូលប្រភេទវត្ថុបុរាណ និងវត្ថុជាតិពន្ធវិទ្យានៃប្រទេសកម្ពុជា» និងកាត់បន្ថយការលួចប្លន់នៃវត្ថុបុរាណដ៏ល្អឯក ពីប្រទេសកម្ពុជា។ ការបន្ត MOU នេះនឹងបន្តការផ្លាស់ប្តូរគ្នា នូវវត្ថុបុរាណ និងវត្ថុជាតិពន្ធសាស្ត្រ សម្រាប់បំណងផ្នែកវប្បធម៌ អប់រំ និងវិទ្យាសាស្ត្រ ដើម្បីធ្វើឲ្យសាធារណជនកាន់តែយល់ និងផ្តល់តម្លៃ ហើយស្វែងយល់បាននូវបេតិកភណ្ឌវប្បធម៌ដ៏សម្បូរបែបរបស់កម្ពុជា។

ក្នុងរយៈពេល ២០ ឆ្នាំកន្លងមក MOU នេះ បានជួយសម្រួលដល់ការបញ្ជូនត្រឡប់មកកម្ពុជាវិញ នូវវត្ថុបុរាណដ៏មានតម្លៃចំនួនជាង ១០០ ដុំ និងបានកសាងសមត្ថភាពរបស់ជនជាតិខ្មែរ ដែលធ្វើការងារថែរក្សាគាំពារបេតិកភណ្ឌវប្បធម៌៕

# យូនីសេហ្វ និងចិន រួមគ្នាអនុវត្តសាកល្បងបច្ចេកវិទ្យាទឹកស្អាតនិងអនាម័យ ដែលធន់នឹងអាកាសធាតុនៅកម្ពុជា

*អត្ថបទ៖ អមរិន្ទ ដានុត*

គណៈប្រតិភូមកពីសាធារណរដ្ឋប្រជាមានិតចិន យូនីសេហ្វប្រចាំកម្ពុជា និងយូនីសេហ្វប្រចាំសាធារណរដ្ឋប្រជាមានិតចិនបានចាប់ផ្ដើមដំណើរទស្សនកិច្ចចុះមូលដ្ឋានរយៈពេលបីថ្ងៃនៅក្នុងប្រទេសកម្ពុជា ដើម្បីធ្វើការសិក្សាលទ្ធភាពនៃការសាកល្បងបច្ចេកវិទ្យា និងដំណោះស្រាយទឹកស្អាតនិងអនាម័យដែលធន់នឹងអាកាសធាតុនៅក្នុងប្រទេសកម្ពុជា។




យោងតាមសេចក្ដីប្រកាសព័ត៌មានរបស់យូនីសេហ្វប្រចាំកម្ពុជា បានឱ្យដឹងថា ដោយសហការជាមួយក្រសួងកសិកម្ម និងកិច្ចការជនបទ និងក្រសួងធនធានទឹកនៃសាធារណរដ្ឋប្រជាមានិតចិន យូនីសេហ្វ កំពុងតែអភិវឌ្ឍកម្មវិធីបច្ចេកវិទ្យាទឹកស្អាតនិងអនាម័យទូលំទូលាយមួយដែលបង្ហាញពីដំណោះស្រាយប្រកបដោយភាពច្នៃប្រឌិតរបស់សាធារណរដ្ឋប្រជាមានិតចិន ដែលមានភាពធន់នឹងអាកាសធាតុ និងសន្សំសំចៃថាមពល។

បេសកកម្មសិក្សាលទ្ធភាពនៅកម្ពុជាមានគោលដៅប្រើប្រាស់ជំនាញបច្ចេកទេសរបស់សាធារណរដ្ឋប្រជាមានិតចិនលើការផ្គត់ផ្គង់ទឹកដែលប្រើថាមពលពន្លឺព្រះអាទិត្យ ការបន្សុទ្ធទឹក និងប្រព្រឹត្តកម្មសំណល់លាមកនៅក្នុងតំបន់ទីប្រជុំជន និងជនបទ ដើម្បីជួយកំណត់ពីចំណុចខ្វះខាតផ្នែកបច្ចេកវិទ្យា និងហេដ្ឋារចនាសម្ព័ន្ធ។

លោកបណ្ឌិត វីល ផាកស៍នាយកយូនីសេហ្វប្រចាំកម្ពុជា ថ្លែងថា ការប្រែប្រួលអាកាសធាតុគឺជាវិបត្តិសិទ្ធិកុមារមួយ។ សន្ទស្សន៍ហានិភ័យអាកាសធាតុចំពោះកុមារ (Children's Climate Risk Index)បានចាត់ថ្នាក់កម្ពុជាជាប្រទេសទីបីក្នុងចំណោមប្រទេសនានាដែលប្រឈមមុខនឹងហានិភ័យខ្ពស់ពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។

លោកបន្តថា កុមារទទួលរងផលប៉ះពាល់យ៉ាងខ្លាំងពីការខ្វះខាតទឹក ទឹកជំនន់តាមដងទន្លេ និងជំងឺដែលបង្កឡើងដោយភ្នាក់ងារចម្លងរោគក្នុងចំណោមភាពតានតឹងផ្នែកអាកាសធាតុ និងបរិស្ថានផ្សេងៗទៀត។

លោកបានថ្លែងថា ៖ «យើងសូមអរគុណចំពោះសាធារណរដ្ឋប្រជាមានិតចិន និងយូនីសេហ្វប្រចាំប្រទេសចិន ដែលបានផ្ដល់ការគាំទ្រក្នុងការអនុវត្តការឆ្លើយតបប្រកបដោយនវានុវត្តន៍ និងមានភាពធន់ចំពោះអាកាសធាតុ ដែលបង្កើតបរិស្ថានប្រកបដោយនិរន្តរភាពសម្រាប់សហគមន៍ដែលងាយរងគ្រោះបំផុត»។

ប្រភពដដែលបានលើកឡើងដែរថា នៅក្នុងប្រទេសកម្ពុជា ប្រជាជនម្នាក់ក្នុងចំណោមបួននាក់នៅតាមទីជនបទ នៅតែមិនអាចទទួលបានប្រភពទឹកស្អាត និងអនាម័យប្រសើរជាងមុន ដែលបង្កហានិភ័យដល់សុខភាពសាធារណៈ រារាំងដល់ការអភិវឌ្ឍ និងបណ្ដាលឱ្យមានហានិភ័យនៃភាពកខ្វក់ចំពោះធនធានទឹក ។ សេវាទឹកស្អាតនិងអនាម័យមានភាពងាយរងគ្រោះយ៉ាងខ្លាំងពីការប្រែប្រួលអាកាសធាតុតាមរដូវកាលដោយការទទួលបានទឹករបស់ប្រជាជននៅតាមជនបទពីរដូវវស្សាដល់រដូវប្រាំង មានការថយចុះចំនួន ២២ ភាគរយ ប្រៀបធៀបនឹង ២ ភាគរយនៅក្នុងតំបន់ទីប្រជុំជន ។

លោក ណេណាដ រ៉ាដុនជិក នាយកស្ដីទីរបស់យូនីសេហ្វប្រចាំប្រទេសចិន បានលើកឡើងដែរថា យូនីសេហ្វប្រចាំសាធារណរដ្ឋប្រជាមានិតចិន កំពុងធ្វើការយ៉ាងជិតស្និទ្ធជាមួយដៃគូរបស់យើង ដើម្បីជំរុញសហប្រតិបត្តិការអន្តរជាតិស្ដីពីសិទ្ធិកុមារ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។

«កិច្ចសហការរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិននេះ គឺជាគំរូដ៏ល្អមួយនៃរបៀបដែលយើងអាចដើរតួជាអ្នកសម្របសម្រួលសម្រាប់ការផ្លាស់ប្ដូរចំណេះដឹង និងសហប្រតិបត្តិការបច្ចេកទេសក្នុងវិស័យទឹកស្អាតនិងអនាម័យអាកាសធាតុ និងបរិស្ថាន ដើម្បីជួយដោះស្រាយបញ្ហាប្រឈមរួមនិងធ្ងន់ធ្ងរដែលប៉ះពាល់ដល់កុមារនៅទូទាំងសកលលោក»។ លោក ណេណាដ រ៉ាដុនជិក បានបញ្ជាក់។

គេបានប៉ាន់ស្មានថា ជាងមួយភាគបួននៃប្រជាជនកម្ពុជារងផលប៉ះពាល់ដោយបញ្ហាបរិស្ថានអនាម័យ រស់នៅក្នុងតំបន់ដែលប៉ះពាល់ដោយទឹកជំនន់ ទឹកក្រោមដីកម្រិតខ្ពស់និងប្រឈមមុខនឹងឧបសគ្គផ្សេងៗទៀតក្នុងការទទួលបានអនាម័យប្រកបដោយប្រសិទ្ធភាព រួមទាំងការគ្រប់គ្រងសំណល់លាមកមិនបានត្រឹមត្រូវ។

គម្រោងសហប្រតិបត្តិការកម្ពុជា-ចិន លើផ្នែកទឹកស្អាត និងអនាម័យដែលមានភាពធន់ចំពោះអាកាសធាតុ គឺជាផ្នែកមួយនៃកម្មវិធីសហប្រតិបត្តិការភាគខាងត្បូង-ខាងត្បូង (South-South Cooperation Programme) រវាងប្រទេសទាំងពីរ និងយូនីសេហ្វ៕

# ការធ្វើប័ណ្ណបើកបរម៉ូតូកម្លាំងពី«60CC»ឡើង ជាការសិក្សាសម្រាប់អនុវត្តពេលអនាគត

*អត្ថបទ៖ អមរិន្ទ ដានុត*

អ្នកនាំពាក្យក្រសួងមហាផ្ទៃ នៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២៣ បានធ្វើការពន្យល់ថា ការលើកឡើងរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជុំវិញ «ការសិក្សាធ្វើប័ណ្ណបើកបរទោចក្រយានយន្ត (ម៉ូតូ) ដែលមានកម្លាំងចាប់ពី«60CC»ឡើងទៅ ដើម្បីចូលរួមទប់ស្កាត់គ្រោះថ្នាក់ចរាចរណ៍ទាំងបច្ចុប្បន្ន និងអនាគត។

យោងតាមសេចក្ដីប្រកាសព័ត៌មានរបស់អ្នកនាំពាក្យបានឱ្យដឹងថា លោក ស សុខា រដ្ឋមន្ត្រីក្រសួងមហាផ្ទៃថ្លែងពីការសិក្សានេះក្នុងពិធីប្រកាសចូលកាន់តំណែង និងបំពាក់ឋានន្តរស័ក្តិ នាយឧត្តមសេនីយ៍ដល់អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ នៅទីស្ដីការក្រសួងមហាផ្ទៃ។

សេចក្ដីប្រកាសបញ្ជាក់ថា ៖ «ក្រោយពីការដកស្រង់ពុំបានពេញលេញស៊ីជម្រៅ និងផ្សព្វផ្សាយអនុសាសន៍របស់ ឯកឧត្តមអភិសន្តិបណ្ឌិត បានធ្វើឱ្យមតិសាធារណៈមានការយល់ច្រឡំ និងសម្ដែងទស្សនៈផ្សេង»។

អ្នកនាំពាក្យក្រសួងមហាផ្ទៃ បន្តថា សិក្សាសម្រាប់អនាគត៖ ជាស្មារតីអនុសាសន៍របស់លោកគឺ លោកចង់សង្កត់ធ្ងន់ថា ជាការសិក្សាឡើងវិញនូវបទពិសោធន៍ដែលបានអនុវត្តកន្លងទៅ និងលទ្ធផល ដែលទទួលបានពីការអនុវត្តនោះ។

ប្រភពដដែលថា ៖ «ការសិក្សានេះ គឺសម្រាប់អនុវត្តនាពេលអនាគត ពោលគឺ ប្រសិនការសិក្សារកឃើញថា គ្រោះថ្នាក់ចរាចរណ៍កើតឡើងលើអ្នកប្រើប្រាស់ម៉ូតូ មានអត្រាច្រើនគួរកត់សម្គាល់នោះ ក្រសួងមហាផ្ទៃ នឹងលើកមូលដ្ឋាននេះ ដើម្បីស្នើពិភាក្សាជាមួយ ក្រសួងសាធារណការ និងដឹកជញ្ជូន ដែលមានសមត្ថកិច្ចសម្រេចនិងធ្វើប័ណ្ណបើកបរ»។

សេចក្ដីប្រកាសបានបន្តថា ៖ «ជារួម ពុំមែនជាលក្ខខណ្ឌដាច់ខាត ឱ្យតែម៉ូតូមានកម្លាំងចាប់ពី «60CC»ឡើង គឺសុទ្ធតែតម្រូវឱ្យមានប័ណ្ណបើកបរនោះទេ ពោលគឺ ត្រូវពិនិត្យទៅតាមប្រភេទនៃយាននោះផងដែរ ដូចជា ប្រភេទ ក, ខ,... ជាដើម និងត្រូវគិតគូរអនុវត្តជាជំហានៗបែបណាឱ្យស្របតាមស្ថានភាពសង្គមជាក់ស្ដែង»។

ហេតុផលនៃអនុសាសន៍ របស់ឧបនាយករដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានលើកឡើងយ៉ាងច្បាស់ៗប្រកបដោយការព្រួយបារម្ភថា មិនទាន់ដាច់ ឆ្នាំ២០២៣ផង ចំនួនអ្នកស្លាប់ដោយសារគ្រោះថ្នាក់ចរាចរណ៍មានជាង ១ ១០០ នាក់ឡើយ បើធៀបនឹងចំនួនប្រជាពលរដ្ឋទាំងមូលប្រមាណ១៧លាននាក់។ ដូច្នេះ ទំរាំដាច់ឆ្នាំថ្ងៃឲ្យអាចនឹង កើនឡើងច្រើនជាងនេះក៏ថាបាន បើពុំមានវិធានការគត់មត់។

សេចក្ដីប្រកាសថា ៖ «ជាផែនការ ឯកឧត្តមអភិសន្តិបណ្ឌិត មានទស្សនវិស័យកាត់បន្ថយចំនួនអ្នកស្លាប់ដោយសារ គ្រោះថ្នាក់ចរាចរណ៍ ឱ្យស្ថិតនៅចំនួនមួយទាបបំផុតនាថ្ងៃអនាគត ក្នុងចេតនាបង្ការទប់ស្កាត់កាត់បន្ថយអត្រាស្លាប់ដោយសារគ្រោះថ្នាក់ចរាចរណ៍ផង និងពង្រឹងសណ្ដាប់ធ្នាប់ចរាចរណ៍តាមដងផ្លូវផង»។

ទាក់ទងនឹងករណីនេះ លោក គឹម បញ្ញា នាយកប្រតិបត្តិអង្គការបង្ការរបួសអាស៊ី បានបង្ហាញការគាំទ្រនូវការលើកឡើងរបស់លោក ស សុខា ដើម្បីលើកកម្ពស់សុវត្ថិភាពចរាចរណ៍របស់ប្រជាពលរដ្ឋកម្ពុជា។

លោកបានបញ្ជាក់ថា ៖ «ក្នុងនាមជាអ្នកធ្វើការលើកកម្ពស់សុវត្ថិភាពចរាចរណ៍នៅក្នុងប្រទេសកម្ពុជា ការបណ្ដុះបណ្ដាល ការផ្សព្វផ្សាយអប់រំ និងការកំណត់តម្រូវ ឱ្យមានបណ្ណបើកបរ ក្នុងចំណោមអ្នកជិះម៉ូតូ គឺជាវិធានការដ៏សំខាន់ ក្នុងការរួមចំណែកការស្លាប់ និងរងរបួស ដោយសារគ្រោះថ្នាក់ចរាចរណ៍នៅក្នុងប្រទេសកម្ពុជា»។

ចំណែក អគ្គលេខាធិការនៃរាជបណ្ឌិត្យសភាកម្ពុជា លោក យង់ ពៅ បានសរសេរលើបណ្ដាញសង្គមហ្វេសប៊ុករបស់លោកថា ៖ «គិតបញ្ឈប់ឈ្នួញគ្រាក់ៗ គ្រឿងញៀន មុនគិតធ្វើប័ណ្ណបើកបរម៉ូតូ។ ប័ណ្ណបើកបរម៉ូតូ គិតមិនទាន់កើតព្រោះ សេវាដឹកជញ្ជូនសាធារណៈ មិនអាចគ្របដណ្ដប់បាននៅឡើយ។ ដូច្នេះ ក្មេងៗពិបាកទៅសាលារៀន»៕






# អង្គការអន្តរជាតិ៖ ស្រោចស្រង់ជាបន្ទាន់នូវការថយចុះអត្រាបំបៅកូនដោយទឹកដោះម្ដាយនៅកម្ពុជា

អត្ថបទ៖ អមរិន្ទ ដានុត

យូនីសេហ្វ អង្គការទស្សនៈពិភពលោកអន្តរជាតិ និងដៃគូនានា បានធ្វើការព្រមានពីការថយចុះយ៉ាងគំហុកនៃអត្រាបំបៅកូនដោយទឹកដោះម្ដាយនៅកម្ពុជា ដូចបង្ហាញឱ្យឃើញក្នុងការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជាចុងក្រោយ ២០២១-២០២២ ។



ការអង្កេតនេះបង្ហាញថា ការបំបៅកូនដោយទឹកដោះម្ដាយភ្លាមៗក្រោយសម្រាលពោលគឺការ ផ្ដល់ទឹកដោះម្ដាយដល់ទារកក្នុងអំឡុង ១ ម៉ោងដំបូងក្រោយសម្រាល បានថយចុះពី ៦៦% មក ៥៤% ក្នុងទសវត្សរ៍ចុងក្រោយនេះ ខណៈពេលដែលការបំបៅកូនដោយទឹកដោះម្ដាយតែមួយមុខគត់ ពោលគឺការផ្ដល់តែទឹកដោះម្ដាយជាអាហារសម្រាប់ទារកនៅក្នុងរយៈពេល ៦ ខែដំបូងនៃជីវិតថយចុះពី ៧៤% មក ៥០%។

អង្គការទស្សនៈពិភពលោកបានលើកឡើងថា លទ្ធផលទាំងនេះ គឺជាការគួរឱ្យបារម្ភ ត្បិតការបំបៅកូនដោយទឹកដោះម្ដាយ គឺជាវិធីមួយក្នុងចំណោមវិធីដែលមានប្រសិទ្ធភាពបំផុត ដើម្បីជួយឱ្យកុមាររស់រាន និងមានសុខភាពមាំមួន នៅពេលជីវិតរបស់ពួកគេបានចាប់ផ្ដើម។

បើតាមការប៉ាន់ប្រមាណជាសកល គេអាចសង្គ្រោះជីវិតកុមារប្រមាណ ៨២0.000 នាក់ជារៀងរាល់ឆ្នាំ ប្រសិនបើការបំបៅកូនដោយទឹកដោះម្ដាយមានការកើនឡើងរហូតដល់កៀកនឹងកម្រិតសកល។ ការបំបៅកូនដោយទឹកដោះម្ដាយ ក៏ជួយដល់ការរៀនសូត្ររបស់កុមារ និងបង្ការភាពធាត់ជ្រុល និងជំងឺរ៉ាំរ៉ៃនៅពេលដែលកុមារកាន់តែចម្រើនវ័យនៅក្នុងជីវិតផងដែរ។

លោក វីល ផាកស៍ នាយកយូនីសេហ្វប្រចាំប្រទេសកម្ពុជា ថ្លែងថា ទឹកដោះម្ដាយ គឺជាអំណោយដ៏ពិសិដ្ឋមួយ ដែលម្ដាយអាចផ្ដល់ឱ្យកូនរបស់ខ្លួន។ ទារកបៅទឹកដោះម្ដាយច្រើនតែបន្តរស់រាន ទទួលបានការការពារកាន់តែប្រសើរទប់ទល់នឹងជំងឺដែលបង្កការគំរាមកំហែងដល់ជីវិត និងអាចចម្រើនវ័យក្លាយជាមនុស្សពេញវ័យដែលមានសុខភាពមាំមួន។

លោកបន្តថា ៖ «យើងត្រូវបន្តការប្ដេជ្ញាចិត្តរបស់យើង ក្នុងការកសាងនូវបរិយាកាសកាន់តែប្រសើរ ដើម្បីផ្ដល់ឱ្យស្ត្រីជាម្ដាយនូវចំណេះដឹង និងលទ្ធភាពបំបៅកូនដោយទឹកដោះម្ដាយក្នុងគ្រប់កាលៈទេសៈទាំងអស់ ចាប់ពីពេលដែលកូនទើបសម្រាលនៅមណ្ឌលសុខភាព រហូតដល់ក្នុងគេហដ្ឋាន និងកន្លែងធ្វើការរបស់ម្ដាយ»។

ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ២០២១-២២ រកឃើញថា កត្តាជាច្រើនដែលអាចរួមចំណែកនាំឱ្យអត្រាបំបៅកូនដោយទឹកដោះម្ដាយមានការថយចុះ មានដូចជា ការបន្តផ្សព្វផ្សាយយ៉ាងគំហុកនៃផលិតផលជំនួសទឹកដោះម្ដាយ ដូចជា ម្សៅទឹកដោះគោទារកជាដើម កង្វះការយល់ដឹងអំពីអត្ថប្រយោជន៍នៃការបំបៅកូនដោយទឹកដោះម្ដាយដែលមានច្រើនជាងម្សៅទឹកដោះគោទារក និងការគាំទ្រតិចតួចដល់ម្ដាយដែលកំពុងបំបៅដោះកូន ពេលដែលពួកគេវិលចូលធ្វើការវិញ។

ការថយចុះការបំបៅកូនដោយទឹកដោះម្ដាយត្រូវបានគេសង្កេតឃើញថា មានការថយចុះរួចទៅហើយ សូម្បីតែមុនពេលដែលមានការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩ ។

លោកស្រី ក្រាណា ពូ សេរី ប្រធានបច្ចេកទេសផ្នែកអាហារូបត្ថម្ភ នៃអង្គការទស្សនៈពិភពលោកអន្តរជាតិ នៅកម្ពុជា ថ្លែងដែរថា ការបំបៅកូនដោយទឹកដោះម្ដាយ គឺជាការទទួលខុសត្រូវរួម ហើយចាំបាច់ត្រូវមានការគាំទ្រពីគ្រប់ផ្នែកទាំងអស់នៃសង្គម។

ចំណែក លោកស្រី ប្រាក់ សោភ័ណនារី រដ្ឋលេខាធិការក្រសួងសុខាភិបាល លើកឡើងដែរថា ក្រសួងសុខាភិបាលបាននិងកំពុងអនុវត្តសកម្មភាពជាច្រើន ដើម្បីលើកទឹកចិត្តឱ្យមានការអនុវត្តទម្លាប់ចិញ្ចឹមទារក និងកុមារតូចឱ្យបានល្អបំផុត ដូចជាការអនុវត្តគំនិតផ្ដួចផ្ដើមមណ្ឌលសុខភាពស្រឡាញ់ទារក និងគោលនយោបាយជាតិស្ដីពីការចិញ្ចឹមទារក និងកុមារតូច ជាដើម។

លោកស្រីថា ៖ «យើងក៏សូមលើកទឹកចិត្តឱ្យបុគ្គលិកសុខាភិបាលទាំងអស់អនុវត្តតាមអនុក្រឹត្យលេខ ១៣៣ ស្ដីពីទីផ្សារផលិតផលសម្រាប់ទារក និងអាហារបំប៉នសម្រាប់កុមារ និងចូលរួមការពារ លើកកម្ពស់ និងគាំទ្រដល់ការបំបៅកូនដោយទឹកដោះម្ដាយនៅតាមកន្លែងធ្វើការរបស់ពួកគេ»។

ដើម្បីឆ្លើយតបចំពោះការថយចុះគួរឱ្យបារម្ភនៃអត្រាបំបៅកូនដោយទឹកដោះម្ដាយ ដៃគូនៃចលនាបង្កើនអាហារូបត្ថម្ភនៅកម្ពុជា កំពុងធ្វើការរួមគ្នា ដើម្បីជួយដល់រដ្ឋាភិបាល ក្នុងការពង្រឹងការអនុវត្តលិខិតបទដ្ឋានគតិយុត្ត ស្ដីពីការផ្សព្វផ្សាយលក់ផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ ឱ្យបានកាន់តែខ្លាំងក្លាបន្ថែមទៀត៕

# ប្រទេសអង់គ្លេស អនុម័តថ្នាំព្យាបាលជំងឺមហារីក

អ្នកជំងឺមហារីករាប់ពាន់នាក់នៅក្នុងប្រទេសអង់គ្លេស នឹងក្លាយជាមនុស្សដំបូងគេក្នុងពិភពលោក ដែលទទួលថ្នាំព្យាបាលជំនាន់ថ្មី ដែលប្រើប្រាស់ពេលវេលាតែ ៧នាទី ជំនួសឱ្យការចាក់បញ្ចូលរយៈពេល ១ ម៉ោងពីមុន។

សេវាសុខភាពជាតិអង់គ្លេស NHS បាននិយាយថា អ្នកជំងឺរហូតដល់ ៣,៦០០ នាក់ ក្នុងមួយឆ្នាំៗដូចជា៖ មហារីកសួត ប្លោកនោម មហារីកសុដន់ ឬថ្លើម នឹងអាចទទួលបានអត្ថប្រយោជន៍ពីការផ្លាស់ប្ដូរថ្មីនេះ។ ជម្រាបដែរថា បច្ចុប្បន្ននេះថ្នាំប្រភេទ immunotherapy ដែលមានឈ្មោះថា Atezolizumab ឬ Tencentriq មានតែនៅតាមមន្ទីរពេទ្យប៉ុណ្ណោះ ដោយការចាក់បញ្ចូលថ្នាំទៅក្នុងសរសៃឈាម។

ជាធម្មតា Atezolizumab ត្រូវចំណាយពេល ៣០នាទី ប៉ុន្តែសម្រាប់អ្នកជំងឺខ្លះ វាអាចចំណាយពេលដល់ ១ម៉ោង នៅពេលដែលថ្នាំពិបាកចូលទៅក្នុងសរសៃឈាមវ៉ែនរបស់ពួកគេ។ ប៉ុន្តែឥឡូវនេះ អ្នកជំងឺមហារីកដែលទទួលយកការព្យាបាលថ្មី ដោយការចាក់បញ្ចូលទៅក្រោមស្បែក នឹងអាចកាត់បន្ថយពេលវេលារហូតដល់ ៧៥% ឯណោះ។

វាត្រូវបានគេនិយាយថា ជាបទពិសោធន៍ដែលកាន់តែមានផាសុកភាព ហើយនឹងធ្វើឱ្យបុគ្គលិកពេទ្យមិនចំណាយពេលច្រើនដូចមុន ដែលអនុញ្ញាតឱ្យពួកគេអាចព្យាបាលអ្នកជំងឺបានកាន់តែច្រើនជារៀងរាល់ថ្ងៃ ហើយវាក៏ជួយកាត់បន្ថយការរង់ចាំរបស់អ្នកជំងឺផងដែរ។

ការព្យាបាលដោយ Atezolizumab ជួយឱ្យប្រព័ន្ធភាពស៊ាំរបស់អ្នកជំងឺមានសមត្ថភាពក្នុងការស្វែងរក និងសម្លាប់កោសិកាមហារីក។ ការព្យាបាលបច្ចុប្បន្ន គឺដោយការចាក់បញ្ចូលទៅក្នុងសរសៃឈាម ហើយត្រូវចំណាយពេលច្រើនចាប់ពី ៣០នាទី ទៅ ១ម៉ោង ខណៈដែលការព្យាបាលប្រភេទថ្មី នឹងចំណាលពេលត្រឹមតែ ៧នាទី ដោយវិធីសាស្ត្រចាក់បញ្ចូលទៅក្រោមស្បែក។

យ៉ាងណាក៏ដោយ អ្នកជំងឺមហារីកដែលទទួលថ្នាំ Atezolizumab និងព្យាបាលដោយគីមីបញ្ចូលគ្នា នឹងត្រូវបន្តចាក់ថ្នាំតាមសរសៃឈាមដដែល។ ការព្យាបាល Atezolizumab ក្នុងទម្រង់ថ្មីនេះ ត្រូវបានអនុម័តឱ្យប្រើប្រាស់ដោយភ្នាក់ងារនិយតកម្មឱសថ និងផលិតផលថែទាំសុខភាពអង់គ្លេស៕ *(អត្ថបទ៖ កោះសន្តិភាព)*



# ព្រៃត្រូពិចត្រូវកំហែង ដោយកំដៅ




យោងតាមការសិក្សាមួយដែលផ្សព្វផ្សាយនៅក្នុងព្រឹត្តិបត្រធម្មជាតិ បានឲ្យដឹងថា ការប្រែប្រួលអាកាសធាតុប្រឈមនឹងធ្វើឱ្យព្រៃត្រូពិចទទួលរងសីតុណ្ហភាពដែលខ្ពស់ខ្លាំងដើម្បីអាចឲ្យរស្មីសំយោគដំណើរការបាន។

ព្រៃត្រូពិចមិនគ្រាន់តែទទួលការគំរាមកំហែងពីការកាប់បំផ្លាញ និងគ្រោះរាំងស្ងួតនោះទេ។ ការប្រែប្រួលអាកាសធាតុក៏ផ្ដល់ហានិភ័យនឹងធ្វើឲ្យពួកវា ទទួលរងសីតុណ្ហភាពដែលខ្ពស់ខ្លាំងពេកដើម្បីអាចធ្វើឱ្យរស្មីសំយោគដំណើរការតាមធម្មតា។

លោក គ្រីស្តូហ្វឺ ឌូធី ពីសកលវិទ្យាល័យអារីហ្សូណាខាងជើង សហរដ្ឋអាម៉េរិក បានពន្យល់ថា ៖ «ប្រសិនបើកម្ដៅក្នុងខ្យល់កើនពី២°C ទៅ៣°C សីតុណ្ហភាពនៃផ្ទៃស្លឹកកើន ៨ដង»។ ជាមួយនឹងការកើនឡើងនូវសីតុណ្ហភាពមធ្យម ៤°C ពីសីតុណ្ហភាពសព្វថ្ងៃ ឬជាមួយនឹងទិសដៅអាកាសធាតុដែលគេវាយតម្លៃថា អាក្រក់បំផុត លោកគ្រីស្តូហ្វឺ ឌូធី បានប្រាប់ថា យើងនឹងឃើញការស្លាប់ទាំងស្រុងរបស់ស្លឹករុក្ខជាតិ។

ការស្លាប់នេះអាចនឹងក្លាយជាកត្តាបន្ថែមនៃការបម្រែប្រែដែលប្រកាសថា ព្រៃត្រូពិចមួយភាគនឹងក្លាយជាទេសភាពវាលស្មៅបន្ថែមពីក្រោមឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ និងការកាប់បំផ្លាញព្រៃឈើ។

បើយោងតាមអ្នកសិក្សាស្រាវជ្រាវ បានឲ្យដឹងថា ប្រសិនបើសីតុណ្ហភាពខ្យល់កើនឡើងបន្ត 0,03 °C ការស្លាប់ដ៏សម្បើមនៃស្លឹករុក្ខជាតិអាចនឹងកើតមានឡើងក្នុងរយៈពេល ១សតវត្ស។

លោកចូស្ស ហ្វ៊ីស្ហើ ពីសកលវិទ្យាល័យចាបមេន និងជាសហនិពន្ធនៃការសិក្សាក៏បានទទូចថា ការរកឃើញអត្រាដ៏តូចនៃដើមឈើខ្ពស់ៗ ដែលឡើងកម្ដៅគឺជាសញ្ញាព្រមានជាមុន ដែលត្រូវជម្រុញឱ្យមានប្រតិកម្ម៕



## បទយកការណ៍៖

# កសិដ្ឋានមួយកន្លែង កំពុងតែកាក់កបខ្លាំង លើរបរចិញ្ចឹមបង្កងអាមេរិក





*អត្ថបទ៖ ម៉ូត ពេជ្យហ្សាលីន*

បច្ចុប្បន្ននេះវិស័យមួយចំនួនធំនៅកម្ពុជា ក៏ដូចជាទូទាំងពិភពលោក សុទ្ធតែកំពុងតែជួបប្រទះនូវផលពិបាកយ៉ាងខ្លាំងដោយសារតែវិបត្តិរាតត្បាតជំងឺកូវីដ១៩ ជាសកល។ ដោយក្រឡេកទៅមើលប្រជាកសិករម្នាក់ កំពុងតែកាកកប់ខ្លាំងលើអាជីពមួយនេះ។

សម្បុរសណ្តែកបាយ និងមានមាឌមាំ លោក អ៊ិន សំណាង បានចាប់អាជីពធ្វើជាអ្នកចិញ្ចឹមបង្កងរយៈពេល៣ឆ្នាំហើយ បានរៀបរាប់ដោយទឹកមុខញញឹមថា លោកបានចាប់ផ្តើមប្រកបរបរនេះតាំងពីឆ្នាំ២០១៩មកម្ល៉េះ។ លោកថា ការចាប់យកមុខរបរនេះ ដោយសារតែមើលឃើញពីទីផ្សារបង្កងទទួលបានការគាំទ្រពីប្រជាពលរដ្ឋទាំងក្នុងស្រុក និងក្រៅស្រុក ខណៈបច្ចុប្បន្ននេះបង្កងក៏មានតម្លៃថ្លៃផងដែរ។

គិតមកដល់ពេលនេះ លោក អ៊ិន សំណាង បានក្លាយទៅជាម្ចាស់កសិដ្ឋានចិញ្ចឹមបង្កង ដែលមានឈ្មោះថា «លក្ខណាបង្កងវាលស្បូវ» ក៏បានរម្លឹកពីទុនដំបូង ដើម្បីចាប់ផ្តើមមុខរបរនេះថា ដំបូងឡើយកសិដ្ឋានរបស់លោកគឺប្រើទុនក្រោម១០០ដុល្លារតែប៉ុណ្ណោះ ហើយដោយកាលណោះលោកបានចាប់ផ្តើមរៀនសូត្របច្ចេកទេសចិញ្ចឹមពីតាមបណ្តារកសិដ្ឋាននានានិងតាមប្រព័ន្ធ YouTube ជាដើម។

បុរសវ័យជាង ៥២ ឆ្នាំរូបនេះ បានបញ្ជាក់បន្តថា មូលហេតុដែលលោកចាប់យកមុខរបរចិញ្ចឹមបង្កងនេះជាមុខរបរចិញ្ចឹមជីវិតសម្រាប់ក្រុមគ្រួសារ ដោយសារចិត្តស្រលាញ់ចូលចិត្តវិស័យកសិកម្ម ម្យ៉ាងមិនចង់ទុកដីឱ្យនៅទំនេរចោល និងការចិញ្ចឹមមិនប៉ះពាល់ដល់បរិស្ថានទៀតផង។ ហេតុនេះទើបលោក សម្រេចធ្វើការជ្រើសរើសចិញ្ចឹមបង្កងអាមេរិក ព្រោះងាយស្រួលជាងបង្កងទឹកសាបហើយប្រមូលផលបានលឿនដោយចាយពេលតែ ៣ខែគឺអាចចាប់លក់បានហើយ។

ចំពោះការចិញ្ចឹមបង្កងអាមេរិកនេះវិញ គឺចាំត្រូវគិតលើកត្តាទឹកជាចំបង ដោយធ្វើយ៉ាងណាទឹកត្រូវមានកម្រិត PH





អាស៊ីត សារធាតុរ៉ែ ត្រឹមត្រូវ បរិស្ថានជុំវិញ ស្អាតគ្មានជាតិពុលជាដើម។ សម្រាប់លោកផ្ទាល់គឺការចិញ្ចឹមបង្កងនេះ គឺធ្វើឡើងក្នុងស្រះធម្មជាតិព្រោះធ្វើបែបនេះធ្វឱ្យបង្កងឆាប់ធំធាត់លឿន និងមានរសជាតិឆ្ងាញ់ ប៉ុន្តែក៏មានផងដែរនូវអាងចិញ្ចឹមជាអាងស៊ីម៉ង់ អាងជ័រ អាងធ្វើពីតង់ជាដើម។ នេះបើតាមការបញ្ជាក់បន្ថែមពី ម្ចាស់កសិដ្ឋានខាងលើនេះ។

ចំពោះការចិញ្ចឹមត្រូវគិតលើកត្តាទឹកជាចំបង ទឹកត្រូវមានកម្រិត PH អាស៊ីត សារធាតុរ៉ែ ត្រឹមត្រូវ បរិស្ថានជុំវិញ ស្អាតគ្មានជាតិពុល។ សម្រាប់លោកផ្ទាល់ ការចិញ្ចឹមបង្កងនេះក្នុងស្រះធម្មជាតិព្រោះឆាប់ធំធាត់លឿន និងមានរសជាតិឆ្ងាញ់ ក៏មានផងដែរនូវអាងចិញ្ចឹមជាអាងស៊ីម៉ង់ អាងជ័រ អាងធ្វើពីតង់ជាដើម។

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ការចិញ្ចឹមបង្កងនៅកម្ពុជា កំពុងតែចាប់ផ្តើមលេចធ្លោខ្លាំង ហេតុនេះហើយទើបកសិដ្ឋានរបស់លោកភាគច្រើនចិញ្ចឹមកូនលក់ជាងលក់សាច់ ដែលកសិដ្ឋានអាចចាប់លក់បានវិលជុំតែម្តងជារៀងរាល់ខែ ដោយចំណូលជាប្រចាំទទួលបានជិត១០០០ដុល្លារដែរពោល គឺចាប់ពី៦០០ដុល្លារ ទៅ៧៥០ដុល្លារ។

ម្ចាស់កសិដ្ឋានរូបនេះបានបញ្ជាក់ដូច្នេះថា ៖ «ជាទូទៅ ដោយលក់បង្កងសាច់ ១ គីឡូ២៧ដុល្លារ មេពូជ១គូ ៣ដុល្លារ មេពង១ក្បាល៣.៥០ដុល្លារ កូន១គ្រាប់លក់រាយ ៧០០រៀល យកច្រើនពាន់ក្បាលតែ ៥៥០រៀល»។

> ខ្ញុំស្នើដល់មន្ត្រីកសិកម្ម សុំជាកម្លាំងចិត្ត ស្វះស្វែងក្នុងការប្រឹក្សាយោបល់ ផ្តល់បច្ចេកទេសដល់កសិករដែលខិតខំដាំនិងចិញ្ចឹមព្រមទាំងជួយផ្សព្វផ្សាយនិងរកទីផ្សារឱ្យកសិករទាំងអស់គ្នា







លោកសំណាងបានគូសបញ្ជាក់ដោយអារម្មណ៍សប្បាយរីករាយផងដែរថា ការចិញ្ចឹមបង្កងអាមេរិកបានជួយជម្រុញកំណើនសេដ្ឋកិច្ចជាតិ ព្រោះបើកាលណាកសិកររកចំណូលបានច្រើនពីការចិញ្ចឹមបង្កងនេះ កាត់បន្ថយភាពក្រីក្រនឹងធ្វើឱ្យសេដ្ឋកិច្ចជាតិរីកចម្រើន ក្នុងន័យនេះ កសិករគឺអាចជួយខ្លួនឯងបានជួយផលិត ជួយដាំដុះ កាត់បន្ថយការនាំចូលពីខាងក្រៅដែលជាបន្ទុករបស់រដ្ឋ។

ទន្ទឹមគ្នានេះតាមរយៈរបរនេះលោកបានបង្ហាញក្តីសង្ឃឹមយ៉ាងមុតមាំដែរថា ប្រជាកសិករជាច្រើននឹងងាកមកចិញ្ចឹមបង្កងនេះ ហើយមានអតិថិជន ជាតិនិងអន្តរជាតិជាច្រើនគាំទ្រ។

លោកក៏បានសំណូមពរទៅកាន់ស្ថាប័នពាក់ព័ន្ធដូច្នេះទៀតថា៖ «ខ្ញុំស្នើដល់មន្ត្រីកសិកម្ម សុំជាកម្លាំងចិត្ត ស្វះស្វែងក្នុងការប្រឹក្សាយោបល់ ផ្តល់បច្ចេកទេសដល់កសិករដែលខិតខំដាំនិងចិញ្ចឹមព្រមទាំងជួយផ្សព្វផ្សាយនិងរកទីផ្សារឱ្យកសិករទាំងអស់គ្នា ហើខ្ញុំក៏សូមស្នើដល់បងប្អូនប្រជាកសិករនៅកម្ពុជាទាំងអស់ដែលមានដីធ្លី សូមកុំទុកទំនេរចោល ព្យាយាមដាំដំណាំ ឬចិញ្ចឹមសត្វដើម្បីជីវភាពគ្រួសារនិងសង្គម។ ម្យ៉ាងខ្ញុំក៏សូមប្រជាពលរដ្ឋខ្មែរ ចូលរួមគាំទ្រផលិតផលខ្មែរស្នាដៃរបស់ខ្មែរ ប្រសើរជាងទទួលទានផលិតផលនាំចូល»។

គួរបញ្ជាក់ផងដែរថា កសិដ្ឋានចិញ្ចឹមបង្កងរបស់លោក អ៊ិន សំណាង មានទីតាំងស្ថិតនៅក្នុងភូមិស្វាយតាអុក សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។ អ្វីដែលកាន់តែពិសេសទៀតនោះ ម្ចាស់កសិដ្ឋានរូបនេះ ក៏បានប្រកាសបង្រៀនស្ម័គ្រចិត្តនូវបច្ចេកទេសចិញ្ចឹមបង្កងនេះដោយឥតគិតថ្លៃផងដែរ ហើយពេលរៀនចប់មានការចែកជូនពូជបង្កង២០០កូនថែមទៀតផង ដែលជាឱកាសពិសេសសម្រាប់សិស្សនិស្សិត កសិករដែលចង់រៀនជំនាញនេះតែគ្មានលទ្ធភាពបង់ប្រាក់សិក្សា។

ដោយឡែក ចំពោះមូលហេតុដែលបង្រៀនដោយស្ម័គ្រចិត្តនេះ ត្រូវបានលោក អ៊ិន សំណាង បានបញ្ជាក់ឱ្យដឹងដែរថា ៖ «ដោយសារតែខ្ញុំកើតមកជាកូនកសិករក្រីក្រ នៅពេលខ្ញុំបានចេះដឹងខ្លះៗហើយ ខ្ញុំអាចមានលទ្ធភាពតិចតួចក្នុងការចូលរួមជួយសង្គម ខ្ញុំនឹងជួយ មុនពេលដែលខ្ញុំស្លាប់ទៅ»៕



# រមណីយដ្ឋាន ប្រាសាទកោះកេរ ត្រូវបានចុះក្នុងបញ្ជី បេតិកភណ្ឌពិភពលោក

*អត្ថបទ៖ អមរិទ្ធ ដានុត*

ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២៣ ក្លាយជាទិវាប្រវត្តិសាស្ត្រដ៏សំខាន់មួយទៀតរបស់ជាតិ និងប្រជាជនកម្ពុជាទាំងមូល ដោយគណៈកម្មាធិការបេតិកភណ្ឌពិភពលោកនៃអង្គការយូណេស្កូ បានសម្រេច ជាឯកច្ឆ័ន្ទចុះ «រមណីយដ្ឋានប្រាសាទកោះកេរ» ទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក។

លោកនាយករដ្ឋមន្ត្រី ហ៊ុន ម៉ាណែត បានលើកឡើងតាមរយៈសារលិខិតផ្ញើជូនជនរួមជាតិ នៅល្ងាចថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២៣ បន្ទាប់ពី «រមណីយដ្ឋានប្រាសាទកោះកេរ» ត្រូវបានចុះក្នុងបញ្ជីបេតិកភណ្ឌ ពិភពលោក នាកិច្ចប្រជុំលើកទី៤៥ របស់ខ្លួន នៅទីក្រុងរីយ៉ាដ (Riyadh)នៃប្រទេសអារ៉ាប៊ីសាអូឌីត។

លោកបានថ្លែងថា ព្រឹត្តការណ៍ថ្មីនេះ គឺជាមោទកភាពមួយទៀត សម្រាប់ប្រជាពលរដ្ឋ និងប្រទេសកម្ពុជាដែលកេរមរតកវប្បធម៌អតីតរាជធានីខ្មែរបុរាណ ឆោកគគ៌្យ ឬលិង្គបុរ ហើយបច្ចុប្បន្នហៅថា កោះកេរ កសាង ក្នុងសតវត្សទី១០ (៩២៨-៩៤៤) ដោយព្រះបាទជ័យវរ្ម័នទី៤ និងបុព្វបុរសខ្មែរ ត្រូវបានក្រុមប្រឹក្សាអន្តរជាតិ ស្តីពីប្រាង្គប្រាសាទ និងរមណីយដ្ឋាន (ICOMOS) ទទួលស្គាល់ថាជាកំពូលស្នាដៃដ៏មហស្ចារ្យនៃស្ថាបត្យកម្ម ខ្មែរ និងមានតម្លៃលេចធ្លោជាសកលដែលចាំបាច់ត្រូវចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោក។

ការស្នើសុំចុះ «រមណីយដ្ឋានប្រាសាទកោះកេរ» ទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក គឺជាលទ្ធផលនៃកិច្ចដំណើរការងារដ៏យូរ និងលំបាកស្មុគស្មាញ ដោយមានការចូលរួមពីភាគីពាក់ព័ន្ធជាច្រើន ជាពិសេសការរៀបចំឯកសារ ការត្រួតពិនិត្យ និងវាយតម្លៃដោយអ្នកជំនាញការជាតិ និងអន្តរជាតិ បានប្រព្រឹត្តទៅក្នុងដំណាក់កាលដែលកម្ពុជា និងពិភពលោកទាំងមូលកំពុងប្រយុទ្ធប្រឆាំងនឹងជម្ងឺកូវីដ-១៩។

ដំណើរការដ៏ស្មិតស្មាញនេះ បានឆ្លុះបញ្ចាំងយ៉ាងច្បាស់អំពីឆន្ទៈដ៏មោះមុតរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការ បញ្ជាក់ពីតម្លៃដ៏មហាសាលនៃសម្បត្តិវប្បធម៌របស់កម្ពុជា ជាពិសេសសម្រេចឱ្យបាននូវការចុះបញ្ជី «រមណីយ ដ្ឋានប្រាសាទកោះកេរ» ទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក សម្រាប់ជាសម្បត្តិមនុស្សជាតិទាំងមូល និងការពង្រឹងមោទកភាពជាតិ។

ការកសាងនូវឯកសារស្នើសុំចុះបញ្ជីបានចាប់ផ្តើមតាំងពីឆ្នាំ២០១៨ មកម្ល៉េះ ដោយឆ្លងកាត់ការរៀបចំ ត្រួតពិនិត្យ និងវាយតម្លៃជាបន្តបន្ទាប់ ដោយមន្ត្រីជំនាញអាជ្ញាធរជាតិព្រះវិហារ និងមន្ត្រីជំនាញក្រោមឱវាទ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ព្រមទាំងការពិគ្រោះយោបល់ជាមួយអ្នកជំនាញការអន្តរជាតិរហូតឆ្នាំ២០២០ ទើបឯកសារនេះបានលេចចេញជារូបរាងឡើង ស្របទៅតាមអនុសញ្ញាស្តីពីការការពារបេតិកភណ្ឌពិភពលោក វប្បធម៌ និងធម្មជាតិ មុននឹងលោក ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រីកម្ពុជា អាណត្តិទី៦ កន្លងទៅ បានសម្រេចលើកសំណើជាផ្លូវការទៅមជ្ឈមណ្ឌល បេតិកភណ្ឌពិភពលោកនៃអង្គការយូណេស្កូ កាលពីខែមករា ឆ្នាំ២០២១។

> យើងមានស្នាដៃបុព្វបុរសខ្មែរ ត្រូវបានបរទេសគេបានយកចិត្តទុកដាក់ យើងជាមនុស្សខ្មែរ កូនខ្មែរ យុវជនខ្មែរ គួរដឹកដៃគ្នា នាំគ្នាសិក្សាពីអ្វីដែលជារបស់ខ្មែរឱ្យបានច្រើនដើម្បីទុកជាកេរតំណែល គំនិត និងចំណេះដឹងសម្រាប់អ្នកបន្តវេនជំនាន់ក្រោយ



រូបភាព៖ ម៉ក់ ភារៈ





ផ្អែកលើសំណើរបស់រាជរដ្ឋាភិបាល មជ្ឈមណ្ឌលបេតិកភណ្ឌពិភពលោករបស់អង្គការយូណេស្កូ បានបញ្ជូនអ្នកជំនាញការអន្តរជាតិនៃក្រុមប្រឹក្សាអន្តរជាតិស្តីពីប្រាង្គប្រាសាទ និងរមណីយដ្ឋាន (ICOMOS) មកធ្វើការវាយតម្លៃដោយផ្ទាល់នៅរមណីយដ្ឋានប្រាសាទកោះកេរ កាលពីខែកញ្ញា ឆ្នាំ២០២១។

រហូតដល់ខែមីនា ឆ្នាំ២០២២ ទើបសម្រេចទទួលយក នូវសំណើសុំចុះបញ្ជី «រមណីយដ្ឋានប្រាសាទកោះកេរ» ទៅដាក់ក្នុងរបៀបវារៈសម័យប្រជុំលើកទី៤៥ របស់ខ្លួន នៅទីក្រុងរីយ៉ាដ (Riyadh)នៃប្រទេសអារ៉ាប៊ីសាអូឌីត ហើយក៏ត្រូវបានគណៈកម្មាធិការបេតិកភណ្ឌ ពិភពលោកសម្រេចចុះ «រមណីយដ្ឋានប្រាសាទកោះកេរ» ក្នុងបញ្ជីបេតិកភណ្ឌពិភពលោកនៅថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ២០២៣ នេះ។

លោក ហ៊ុន ម៉ាណែត បានបញ្ជាក់ថា ៖ «មហាសមិទ្ធផលនេះ គឺជាកិត្យានុភាពដ៏ខ្ពស់ត្រដែតថ្មីមួយទៀតរបស់ជាតិយើងក្នុងឆាកអន្តរជាតិ ដែលកើតចេញមកពីកិច្ចខិតខំប្រឹងប្រែងប្រកបដោយវិរិយភាពជាប់មិនដាច់ និងឥតរាថយរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រោមម្លប់នៃសុខសន្តិភាព ដែលជាសមិទ្ធផលនៃនយោបាយឈ្នះ ឈ្នះរបស់សម្តេចតេជោ ហ៊ុន សែន»។

សម្តេចធិបតី ហ៊ុន ម៉ាណែត ក៏បានអំពាវនាវដល់គ្រប់ស្ថាប័នពាក់ព័ន្ធទាំងអស់ រួមមានអាជ្ញាធរដែនដីខេត្តព្រះវិហារ និងស្ថាប័ននានា ត្រូវពង្រឹងឱ្យបានដាច់ខាតនូវការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍតំបន់រមណីយដ្ឋានប្រាសាទកោះកេរ ស្របតាមគោលការណ៍របស់គណៈកម្មាធិការបេតិកភណ្ឌពិភពលោក។

សម្តេចធិបតី ហ៊ុន ម៉ាណែត ថា ៖ «ទប់ស្កាត់រាល់ការទន្ទ្រានយកដីខុសច្បាប់ ការសាងសង់សំណង់ខុសច្បាប់ ការកាប់បំផ្លាញព្រៃឈើ ការបរបាញ់ សត្វព្រៃ ការរុករក និងជីកកកាយដោយខុសច្បាប់ ដើម្បីលើកតម្លៃ និងថែរក្សារមណីយដ្ឋានប្រាសាទកោះកេររបស់យើង សម្រាប់ជាប្រយោជន៍ដល់ការអភិវឌ្ឍ និងលើកកម្ពស់ជីវភាពប្រជាជន»។

បន្ទាប់ពីកម្ពុជាទទួលបាននូវសមិទ្ធផលថ្មីនេះដែរ លោក Sardar Umar Alam តំណាងអង្គការយូណេស្កូប្រចាំកម្ពុជា បានសម្តែងការអបអរសាទរដល់ប្រទេសកម្ពុជាផងដែរ ចំពោះសមិទ្ធិផលនេះ។



លោកបានលើកឡើងថា ៖ «ការចុះបញ្ជីប្រាសាទកោះកេរ ក្នុងបញ្ជីបេតិកភណ្ឌពិភពលោករបស់អង្គការយូណេស្កូ គឺជាព្រឹត្តិការណ៍ដ៏សំខាន់មួយសម្រាប់កម្ពុជា ដោយបញ្ជាក់ឡើងវិញនូវកិច្ចខិតខំប្រឹងប្រែងរួមគ្នារបស់យើង ដើម្បីការពារ និងលើកកម្ពស់តម្លៃនៃបេតិកភណ្ឌវប្បធម៌ និងការអភិវឌ្ឍប្រកបដោយចីរភាព»។

ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ក៏បានចូលរួមអបអរសាទរ ផងដែរ លោកទ្រង់បានលើកឡើងថា ៖ «អបអរសាទរ រមណីយដ្ឋានបុរាណវិទ្យាកោះកេរ នៃអតីតរាជធានីលិង្គបុរ ឬ ឆោកគគ៌្យរ របស់ព្រះរាជាណាចក្រកម្ពុជា ត្រូវបានចុះក្នុងបញ្ជីសម្បត្តិបេតិកភណ្ឌរូបិយនៃមនុស្សជាតិរបស់អង្គការយូណេស្កូ»។

ព្រអង្គបានបន្តថា ៖ «យើងចងចាំជានិច្ចចំពោះព្រះរាជកិច្ចដ៏ខ្ពស់ខ្ពស់ និងស្មិតស្មាញបំផុត នៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ជម្រុញឲ្យជោគជ័យដ៏ត្រចះត្រចង់នេះ កើតមានឡើង»។

លោក Sardar Umar Alam បានបន្តថា ៖ «ដូចដែលយើងអបអរសាទរ សមិទ្ធផលនេះបើកទ្វារដល់ឱកាសជាច្រើនសម្រាប់ការអភិវឌ្ឍទេសចរណ៍ប្រកបដោយនិរន្តរភាព និងការលើកកម្ពស់ជីវភាពរស់នៅ។ អង្គការយូណេស្កូនឹងបន្តសហការគ្នាជាមួយប្រទេសកម្ពុជាសម្រាប់ការអភិរក្សទីតាំង រួមទាំងតាមរយៈការស្រាវជ្រាវវិទ្យាសាស្ត្រ និងដើម្បីផ្សព្វផ្សាយបេតិកភណ្ឌវប្បធម៌ខ្មែរទៅកាន់ពិភពលោកបន្ថែមទៀត»។

សូមបញ្ជាក់ដែរថា តំបន់ប្រាសាទកោះកេរ ជាតំបន់រមណីយដ្ឋានទី៤របស់កម្ពុជា ដែលត្រូវបានចុះក្នុងបញ្ជីបេតិកភណ្ឌវប្បធម៌ពិភពលោក បន្ទាប់ពីរមណីយដ្ឋានអង្គរ ឆ្នាំ១៩៩២, តំបន់ប្រាសាទព្រះវិហារ ឆ្នាំ២០០៨ និងតំបន់ប្រាសាទសំបូរព្រៃគុក ឆ្នាំ២០១៧។

ប្រជាពលរដ្ឋក្នុងរាជធានីភ្នំពេញ លោក ប៉ែន រ៉ា បានលើកឡើងថា លោកពិតជាមានមោទនភាព ក្នុងនាមប្រជាពលរដ្ឋខ្មែរមួយរូបដែលដឹងថា រមណីយដ្ឋានប្រាសាទកោះកេររបស់ខ្មែរ ត្រូវបានដាក់បញ្ចូលជាសម្បត្តិបេតិកភណ្ឌវប្បធម៌ពិភពលោក។

លោកបានប្រាប់ថា ៖ «ខ្ញុំមិនដឹងថាត្រូវនិយាយយ៉ាងណាទេ តែគ្រាន់តែថាខ្ញុំពិតជាមានមោទនភាពខ្ពស់សម្រាប់កម្ពុជា និងសូមចូលរួមរអបអរសាទរការចុះបញ្ជី រមណីយដ្ឋានប្រាសាទកោះកេរជាសម្បត្តិបេតិកភណ្ឌវប្បធម៌ពិភពលោក នៃអង្គការយូណេស្កូ»។

ចំណែក អ្នកស្រី អ៊ុន រតនា ក៏បានប្រាប់ដែរថា ទោះបីជាអ្នកស្រីធ្លាប់បានទៅមើលប្រាសាទកោះកេរ តែ២ដង ប៉ុន្តែអ្នកស្រីពិតជាសប្បាយចិត្តនៅពេលដែលលឺថា រមណីយដ្ឋានប្រាសាទកោះកេរនេះ ត្រូវបានអន្តរជាតិទទួលស្គាល់ ហើយគេក៏ស្គាល់ប្រទេសកម្ពុជាផងដែរ។

អ្នកស្រីបានលើកឡើងដែរថា ៖ «ខ្ញុំសូមចូលរួមអបអរសាទរជាមួយនឹងរដ្ឋាភិបាល និងក្រសួងពាក់ព័ន្ធដែលបានខិតខំធ្វើឱ្យប្រទេសផ្សេង ក៏ដូចជាអន្តរជាតិស្គាល់ប្រាសាទខ្មែរយើងកាន់តែច្រើន»។

ចំណែក លោក សំបូរ មាណ្ណារ៉ា សាស្ត្រាចារ្យផ្នែកប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា បានលើកឡើងដែរថា នេះជាមោទនភាពរបស់ជាតិខ្មែរ រាជរដ្ឋាភិបាល សង្គមនៃប្រជាជាតិទាំងអស់នៃពិភពលោក។

លោកមានប្រសាសន៍ថា ៖ «ការចុះបញ្ជីចូលជាបេតិកភណ្ឌពិភពលោកនាពេលនេះ ជាការបង្ហាញប្រាប់ទៅពិភពលោកថា យើងមានបេតិកភណ្ឌជាតិដ៏មានតម្លៃ មានបេតិកភណ្ឌសម្រាប់អន្តរជាតិទទួលស្គាល់ ហើយគេនឹងអាចយកចិត្តទុកដាក់សិក្សាព្យាយាមការស្វែងយល់»។

លោកថា ៖ «យើងមានស្នាដៃបុព្វបុរសខ្មែរ ត្រូវបានបរទេសគេបានយកចិត្តទុកដាក់ យើងជាមនុស្សខ្មែរ កូនខ្មែរ យុវជនខ្មែរ គួរដឹកដៃគ្នា នាំគ្នាសិក្សាពីអ្វីដែលជារបស់ខ្មែរឱ្យបានច្រើនដើម្បីទុកជាកេរតំណែល គំនិត និងចំណេះដឹងសម្រាប់អ្នកបន្តវេនជំនាន់ក្រោយ»។

សូមបញ្ជាក់ដែរថា តំបន់ប្រាសាទកោះ ត្រូវបានកសាងឡើងក្នុងសតវត្សទី១០ (៩២៨-៩៤២) រជ្ជកាលព្រះបាទជ័យវរ្ម័នទី៤ ដើម្បីឧទ្ទិសថ្វាយព្រះឥសូរ ក្នុងព្រហ្មញ្ញសាសនា ដែលមានរូបរាងជាពីរ៉ាមីត មាន៧ជាន់ និងមានកម្ពស់៣៥ម៉ែត្រ។

ប្រាសាទនេះ ជាតំបន់មានបុរាណដ្ឋានប្រមាណ ១៦៩ ក្នុងនោះមានប្រសាទចំនួន ៧៦ មានប្រព័ន្ធផ្លូវថ្នល់ ជារាសាស្ត្រ រហាលត្រពាំង និងទំនប់ជាដើម ដែលមានផ្ទៃដីទំហំជាង ៨,៧០០ ហិកតា ដោយគ្របដណ្តប់ភូមិ៣ គឺភូមិរំចេក ភូមិកោះកេរ និងភូមិស្រយង់ជើង នៃខេត្តព្រះវិហារ៕





រូបភាព៖ ម៉ក់ ភារៈ

# ព្រះសហគមន៍រំលឹកចំណងមិត្តភាព៥០០ឆ្នាំនៅកម្ពុជា

*អត្ថបទ៖ សួន ស្រីហួចដាលីស*

សាសនិកដែលក្នុងនោះមានសិស្សនិស្សិត សាស្ត្រាចារ្យ និងអ្នកបួសប្រមាណជិត៨០នាក់ បានចូលរួមសន្និសីទគរុសភាស្ដីពីមិត្តភាព៥០០ឆ្នាំ៖ ព្រះសហគមន៍គ្រីស្តសាសនានិងព្រះរាជាណាចក្រកម្ពុជា ដែលរៀបចំឡើងដោយសមាគមបេសកជនបារាំង រួមជាមួយសមាគមអ្នកប្រវត្តិសាស្រ្តកម្ពុជា និង សាកលវិទ្យាល័យភូមិន្ទភ្នំពេញ ក្នុងគោលបំណងចង់ផ្តោតសំខាន់លើទំនាក់ទំនងរវាង ព្រះរាជាណាចក្រកម្ពុជានិងព្រះសហគមន៍កាតូលិក និងចងក្រងឯកសារប្រវត្តិសាស្រ្តសម្រាប់ព្រះសហគមន៍កាតូលិកនៅកម្ពុជា។

អង្គសន្និសីទនេះធ្វើឡើងកាលពីថ្ងៃទី១៤ ខែកញ្ញាកន្លងទៅនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ នារាជធានីភ្នំពេញ ដោយមានវាគ្មិនប្រវត្តិសាស្រ្តជាសាស្ត្រាចារ្យ អ្នកស្រាវជ្រាវប្រវត្តិសាស្រ្ត និងបូជាចារ្យកាតូលិកបានឡើងធ្វើបទបង្ហាញអំពីរបបគំហើញថ្មីៗនិងឯកសារកាលប្រវត្តិដែលទាក់ទងនឹងព្រះសហគមន៍កាតូលិកនៅកម្ពុជា។

ឯកឧត្តមបណ្ឌិត សាន វឌ្ឍនា អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជននិងកីឡា និងជាប្រធានក្រុមប្រឹក្សាភិបាលនៃសកលវិទ្យាល័យភូមិន្ទភ្នំពេញ មានប្រសាសន៍បើកកម្មវិធីថា ព្រះសហគមន៍កាតូលិកបានចូលរួមជួយដល់សង្គមកម្ពុជាជាច្រើនក្នុងពេលបច្ចុប្បន្ននេះ ជាពិសេសក្នុងវិស័យអប់រំ ដោយមានពីថ្នាក់កម្រិតមត្តេយ្យសិក្សារហូតដល់ឧត្តមសិក្សា ការផ្តល់និវេសនដ្ឋានដល់យុវជន ការថែទាំសុខភាពប្រជាជន ការផ្តល់អាហារូបករណ៍ដល់សិស្សនិងនិស្សិត និងការផ្គត់ផ្គង់ជីវភាពប្រជាជនជាច្រើនទៀត។

លោកបន្ថែមថា ថ្ងៃនេះយើងមានបព្វជិតមកពីសាសនាផ្សេងៗគ្នា រួមទាំងសាស្ត្រាចារ្យ និស្សិតជាតិនិងអន្តរជាតិជាច្រើនបានចូលរួម បានបង្ហាញពីវប្បធម៌នៃការចែករំលែក និងវប្បធម៌នៃការសន្ទនាគ្នារវាងសាសនាផ្សេងគ្នា និងរវាងការយល់ឃើញផ្សេងគ្នា ហើយដែលបង្ហាញថា សង្គមកម្ពុជាយើងជាសង្គមដែលអាចទទួលយក យោគយល់ មានសេរីភាពនៅក្នុងជំនឿសាសនា ដែលជាមូលដ្ឋានក្នុងការរួមដៃគ្នាអភិវឌ្ឍជាតិយើង។

«យើងនៅតែបន្តរឹតចំណងមិត្តភាពរវាងព្រះសហគមន៍គ្រីស្តសាសនានិងប្រជាជាតិកម្ពុជាជាមួយក្តីមេត្តា ករុណា ការអធ្យាស្រ័យ ការយល់យោគ ក្តីស្រឡាញ់ និងសុខដុមនីភាពសម្រាប់ពិភពលោកទាំងមូលដែលត្រូវការបំផុតនាពេលបច្ចុប្បន្ននេះ» ឯកឧត្តមបណ្ឌិតបន្ថែម។

លោកទេសរដ្ឋមន្ត្រីអៀងម៉ាលីទីប្រឹក្សាជាន់ខ្ពស់សមាគមអ្នកប្រវត្តិសាស្ត្រនៅកម្ពុជា និងជាទេសរដ្ឋមន្ត្រីទទួលបន្ទុកដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ថ្លែងនៅក្នុងអង្គជំនួបនេះថា សន្និសីទគរុសភាស្តីពីមិត្តភាព ៥០០ឆ្នាំរវាងព្រះសហគមន៍គ្រីស្តសាសនានិងព្រះរាជាណាចក្រកម្ពុជានៅពេលនេះ មានអត្ថន័យយ៉ាងធំធេងដើម្បីរំលឹកឡើងវិញអំពីអនុស្សាវរីយ៍ជាមិត្តភាពរវាងបារាំងនិងកម្ពុជាក្នុងអំឡុង ៥ សតវត្សរ៍កន្លងមកនេះ។ លោកបានរំឭកថា នៅពាក់កណ្តាលស.វទី ១៧ មកបេសកជនព្រះសហគមន៍កាតូលិកនៃប្រទេសបារាំង មកដល់កម្ពុជា គឺលោកអភិបាលហ្សង់ក្លូដ ម៉ីសដែលបានបង្កើតព្រះវិហារនៅក្រុងលង្វែក។












តាមរយៈសៀវភៅដែលមានចំណងជើងថា វិសាលវិហារនៅស្រុកស្រែ លោកទេសរដ្ឋមន្ត្រីបានរំលឹកថា ការចូលមករបស់ប្រទេសបារាំងនៅកម្ពុជា មិនត្រឹមតែដើម្បីរក្សាភាពគង់វង្សនៃរាជ្យបល្ល័ង្កប៉ុណ្ណោះទេ តែក៏បានជួយឲ្យវិស័យពុទ្ធសាសនានិងវប្បធម៌ខ្មែរបានរីកចម្រើនឡើងផងដែរ ដោយបារាំងបានកសាងសាលាបាលីជាន់ខ្ពស់និងពុទ្ធសាសនបណ្ឌិតក្នុងឆ្នាំ ១៩៣០។

នៅក្នុងជំនួបនេះ មានបង្ហាញនូវឯកសារកាលប្រវត្តិជាច្រើន និងស្នាដៃស្រាវជ្រាវចងក្រងប្រវត្តិសាស្រ្តទាំងថ្មីនិងចាស់មួយចំនួនទាក់ទងនឹងព្រះសហគមន៍កាតូលិកនៅកម្ពុជា។ តាមឯកសារទាំងអស់នោះ បានឲ្យដឹងថា វត្តមានគ្រីស្តសាសនាបានមកដល់ទឹកដីមួយនេះ នៅដើមស.វទី១៦ នៃគ.ស ក្នុងអំឡុងពេលកម្ពុជាធ្វើពាណិជ្ជកម្មជាមួយពួកព័រទុយហ្គាល់។

ព្រះមុនីកុសលបណ្ឌិតយ៉ន សេងយៀត ព្រះសាកលវិទ្យាធិការរងនៃពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ ថ្លែងក្នុងអង្គពិធីថា រយៈពេល៥០០ឆ្នាំកន្លងមកនេះ ទំនាក់ទំនងរវាងព្រះសហគមន៍កាតូលិក និងវត្តអារាមមិនសូវមានភាពជិតស្និទ្ធនឹងគ្នាប៉ុន្មានទេ ប៉ុន្តែរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះយើងមានភាពជិតស្និទ្ធគ្នាខ្លាំង។

ព្រះតេជគុនបន្តថា ជំនួបអន្តរសាសនាដែលសម្តេចព្រះមហាសង្ឃរាជទេវង្សបាននិមន្តចូលរួមនៅក្នុងឆ្នាំ ២០១៧ជាមួយសមាគមសន្តអេជីឌីអូនៅទីក្រុងរ៉ូម បានប្រែទំនាក់ទំនងទៅជាជិតស្និទ្ធខ្លាំង។

ព្រះមុនីកុសលមានដីកាបញ្ជាក់ទៀតថា «យើងបានបន្តទំនាក់ទំនង៥០០ឆ្នាំមកហើយ ហើយយើងក៏នឹងបន្ត៥០០ឆ្នាំទៅខាងមុខទៀត ដោយប្រកាន់គោលការណ៍នៃការគោរពនៅពហុជំនឿ ដែលអាចជួយអ្នកកាន់សាសនាផ្សេងគ្នាអាចរួមគ្នា អាចចូលទៅជិតគ្នាបាន»។

ឯកឧត្តមអភិបាលអូលីវីយ៉េ ជ្មីតហាស្លេ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញជំនាន់ទី២៤ មានប្រសាសន៍ថា ទស្សនវិស័យរបស់ព្រះសហគមន៍កាតូលិក គឺលើកកម្ពស់តម្លៃថ្លៃថ្នូរនៃជីវិតមនុស្សជាតិទាំងអស់ ដោយជឿថា ពួកគាត់ជាតំណាងរបស់ព្រះជាម្ចាស់ និងជាពិសេសព្រះសហគមន៍កាតូលិកយកចិត្តទុកដាក់ដើម្បីផលប្រយោជន៍រួម ដើម្បីឲ្យមានសកម្មភាព សមត្ថភាព និងភាតរភាព និងយកចិត្តទុកដាក់ថែរក្សានិងការពារបរិស្ថានដែលជាអំណោយទានរបស់ព្រះជាម្ចាស់ដើម្បីបម្រើសុខសន្តិភាព។

លោកអភិបាលព្រះសហគមន៍បានបញ្ជាក់ថា ក្នុងឆ្នាំ១៩៨០ ខណៈកម្ពុជាកំពុងមានវិបត្តិនិងមានជំរំជនភៀសខ្លួនក្នុងប្រទេសថៃ អង្គការការីតាកម្ពុជាដែលជាស្ថាប័នរបស់ព្រះសហគមន៍កាតូលិកបានចូលរួមយ៉ាងជិតស្និទ្ធជាមួយរដ្ឋអំណាចកម្ពុជា ធ្វើដំណើររួមជាមួយប្រជាជនក្នុងគ្រារងទុក្ខលំបាក។

លោកអភិបាលបន្ថែមថា ព្រះសហគមន៍កាតូលិកក៏មានទំនាក់ទំនងជាមួយអន្តរសាសនាជាពិសេសរួមជាមួយព្រះពុទ្ធសាសនា ដើម្បីលើកស្ទួយសង្គមឱ្យមានសុខដុមនីកម្មតាមរយៈសកម្មភាពមនុស្សធម៌និងចូលរួមគ្រប់វិស័យនៅក្នុងសង្គម។

លោកបានលើកឡើងទៀតថា កម្មវិធីថ្ងៃនេះជាឱកាសមួយសម្រាប់យុវជនសិក្សារៀនសូត្រ និងអាចជួយឲ្យពួកគេចេះរៀបចំអនាគតសម្រាប់ប្រទេសជាតិ។

លោកសង្ឃឹមថា ពេលអនាគតយើងអាចមានឱកាសផ្សេងទៀតដែលអាចឱ្យមាននិស្សិតដែលកំពុងស្រាវជ្រាវពីប្រវត្តិសាស្រ្ត និងអំពីសាសនានានាអាចយល់ស៊ីជម្រៅចូលក្នុងវប្បធម៌ផ្ទាល់ខ្លួន និងដើម្បីឱ្យយើងរួមគ្នាកសាងសង្គមមួយដែលចេះយល់ចិត្តគ្នា និងធ្វើដំណើរនៅក្នុងសុខដុមរមនានិងកសាងសេចក្តីសុខ។





> យើងនៅតែបន្តរឹតចំណងមិត្តភាពរវាងព្រះសហគមន៍គ្រីស្តសាសនា និងប្រជាជាតិកម្ពុជា ជាមួយក្តីមេត្តា ករុណា ការអធ្យាស្រ័យ ការយល់យោគ ក្តីស្រឡាញ់ និងសុខដុមនីភាពសម្រាប់ពិភពលោក ទាំងមូលដែលត្រូវការបំផុតនាពេលបច្ចុប្បន្ននេះ

ពេជ្រ ស្រីនាថ វ័យ២១ឆ្នាំ ជានិស្សិតឆ្នាំទី៤ ផ្នែកប្រវត្តិវិទ្យានៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដែលបានចូលរួមក្នុងកម្មវិធីនេះ និយាយថា«ខ្ញុំមិននឹកស្មានថាទំនាក់ទំនងរវាងគ្រីស្តសាសនា និងកម្ពុជាមានភាពជិតស្និទ្ធគ្នារហូត៥០០ឆ្នាំទេ ហើយនេះជារឿងថ្មីសម្រាប់ខ្ញុំដែរ។ និងខ្ញុំសប្បាយរីករាយដោយទំនាក់ទំនងសាសនាបានធ្វើឱ្យសង្គមរបស់ខ្ញុំមានភាពរីកចម្រើនទៅមុខ និងជារឿងល្អដែលមានអន្តរសាសនាច្រើននៅក្នុងប្រទេសដែលធ្វើឱ្យយើងរៀនយល់ពីគ្នា និងសាសនាចូលរួមចំណែកជួយដល់សង្គមជួយដល់មនុស្សខ្វះខាត»។

អ្នកឧកញ៉ា គួច ម៉េងលី បានឱ្យដឹងថាថ្ងៃនេះជាប្រវត្តិសាស្រ្តមួយរវាងព្រះសហគមន៍និងព្រះរាជាណាចក្រកម្ពុជាក្នុងទំនាក់ទំនង៥០០ឆ្នាំ។ ការរំឭកពីប្រវត្តិសាស្រ្តនេះយើងរៀនពីគ្នាទាំងវិជ្ជមាននិងអវិជ្ជមាន ដើម្បីយកមកកែកុំឱ្យរស់នៅជាមួយគ្នាមានការប៉ះទង្គិចផ្លូវចិត្តនិងប៉ះទង្គិចនឹងសាសនានិងការរើសអើង។

លោកម៉េងលីបន្តថា ប្រទេសខ្មែរយើងបានរៀនសូត អនុគ្រោះ និងបើកចំហ។ នៅស្រុកខ្មែរមានសេរីភាពកាន់សាសនា និងរស់នៅជាមួយគ្នាប្រកបដោយសុខដុមនីកម្ម។

តាមឯកសារប្រវត្តិព្រះសហគមន៍កាតូលិកនៅកម្ពុជា ដែលចងក្រងដោយលោកបូជាចារ្យប្រ្វង់ស្វ័រ ប៉ុងសូដស៍ បានឲ្យដឹងថា ព្រះសហគមន៍កាតូលិកបានចូលមកក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ១៥៥៥ នៃគ.ស តាមរយៈបព្វជាតិព័រទុយហ្គាល់ម្នាក់ ឈ្មោះហ្គាស្ប៉ា ដាគ្រុស។

បច្ចុប្បន្នព្រះសហគមន៍កាតូលិកនៅប្រទេសកម្ពុជាមានកន្លែងថ្វាយបង្គំនិងព្រះវិហារសរុបចំនួន១០៤កន្លែង និងមានគ្រីស្តបរិស័ទប្រមាណជាង២ម៉ឺននាក់ ក្នុងចំណោមប្រជាជនកម្ពុជាចំនួនជិត១៦លាននាក់៕

# មណ្ឌលលីនដាល់វាផ្តល់ការអប់រំនិងថែទាំកុមារក្រីក្រ

*អត្ថបទ៖ ចាន់ ម៉ានុត*

អគារកម្ពស់២ជាន់ បានស្ថាបនាឡើងដើម្បីទទួលថែទាំកុមារតូច ដែលភាគច្រើនជាកូនៗរបស់កម្មករ-ការិនីរោងចក្រកាត់ដេរ នៅក្នុងភូមិព្រៃទាទី១ សង្កាត់ចោមចៅទី៣ ខណ្ឌពោធិ៍សែនជ័យ នារាជធានីភ្នំពេញ ត្រូវបានដាក់សម្ពោធឲ្យប្រើប្រាស់ ក្រោមអធិបតីភាព លោកអភិបាល អូលីវីយេ ជ្មីតហាស្លេ អភិបាលនៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ និងបងប្អូនគ្រីស្តបរិស័ទ និងពុទ្ធបរិស័ទចូលរួមប្រមាណជា១០០នាក់។ កាលពីថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ។

អគារថ្មីនេះ មានឈ្មោះថាមណ្ឌលលីនដាល់វា ដែលគ្រប់គ្រងដោយក្រុមគ្រួសារបុត្រីនៃមេត្តាករុណាកម្ពុជា។

ក្នុងពិធីសម្ពោធ ដោយមានពិធីថ្វាយអភិបូជាអរព្រះគុណព្រះជាម្ចាស់ លោកអភិបាល អូលីវីយេ ជ្មីតហាស្លេ បានមានប្រសាសន៍ក្នុងធម្មទេសនាថា មណ្ឌលនេះដូចជាភូមិបេថ្លេហិមដ៏តូចមួយដែលជាកន្លែងយ៉ាងពិសេស ដើម្បីទទួលស្វាគមន៍កុមារឲ្យទទួលបានការសិក្សាអប់រំ ហើយជាកន្លែងមួយដែលផ្តល់សេចក្តីស្រឡាញ់ និងថែរក្សាតាមរបៀបព្រះនាងម៉ារី។

លោកអភិបាលបានបន្ថែមថា ស្នាដៃដែលមណ្ឌលមាន សេវាកម្មដែលមណ្ឌលមាន របៀបដែលមណ្ឌលបង្ហាញសេចក្តីស្រលាញ់ដល់កុមារ និងអ្នកជិតខាង គឺមកពីការ លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ពីព្រឹកដល់យប់ និងព្រះនាងម៉ារីជាគំរូមួយដើម្បីថែរក្សាសេចក្តីស្រលាញ់ដែលទទួលពីព្រះជាម្ចាស់។

មណ្ឌលលីនដាល់វា ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ២០០៦ ដោយក្រុមគ្រួសារបុត្រីមេត្តាករុណានៃសន្តរ៉ាំងសង់ដឺប៉ូលនៅលើដីជួលមួយកន្លែង ក្នុងភូមិព្រៃទាទី១នេះដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងសម្រាប់ សុវត្ថិភាព និងការថែទាំកុមារតូច។

ដូនជី ដេសាកូឡា ជូលី ជាប្រធានអង្គការបុត្រីមេត្តាករុណាកម្ពុជាបានឱ្យដឹងថា ក្នុងតំបន់នេះភាគច្រើនមានជនចំណាកស្រុកពីខេត្តផ្សេងៗធ្វើការងារ និងរកចំណូល តាមរោងចក្រនានា ហើយក្រុមគ្រួសារខ្លះគ្មានលទ្ធភាពនិងគ្មានអ្នកមើលថែនិងដឹកជញ្ជូនកូនៗទៅសាលា ដូច្នេះរាល់ថ្ងៃពួកគេបានចាក់សោរពីខាងក្រៅនៅពេលចេញទៅធ្វើការប្ររកសុី ដោយឱ្យកូនៗរបស់ពួកគេនៅក្នុងបន្ទប់ ព្រោះខ្លាចមានបញ្ហាផ្សេងៗ។

សង្កាត់ចោមចៅ ជាតំបន់ឧស្សាហកម្មមួយដែលសំបូរដោយរោងចក្រនិងសហគ្រាស ផលិតនិងនាំចេញទំនិញមួយចំនួន។ ប្រជាជនចំណាកស្រុកពីខេត្តបានផ្តុំគ្នានៅតំបន់នេះមួយចំនួនដោយធ្វើការងារនៅក្នុងរោងចក្រ ធ្វើសំណង់និងរើសអេតចាយ។

រយៈពេល១៤ឆ្នាំកន្លងមកនេះ តម្លៃជួលផ្ទះបានកើនឡើងជាបន្តបន្ទាប់ ហើយក្នុងរដូវវស្សាផ្ទះជួលនោះលិចទឹកជាប្រចាំ ដែលពិបាកបន្តសកម្មភាព។

ដូនជី ដេសាកូឡា ជូលី បន្ថែមថា ដោយការលំបាកនេះ និងតម្រូវការរបស់កុមារ សប្បុរជនជនជាតិខ្មែរមួយរូប បានផ្តល់ដីមួយនេះដល់ក្រុមដូនជីយើង ប្រើប្រាស់លើកិច្ចការធម៌មេត្តាករុណា ហើយក្រុមយើងបានស្វែងរកជំនួយផ្សេងៗ ដើម្បីសាងសង់អគារមួយនេះឡើង រួចរាល់នៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣នេះ។











«មណ្ឌលលីនដាល់វាបានជួយឱ្យកូនរបស់ខ្ញុំចូលសាលា ទទួលការសិក្សារៀនសូត្រតាំងពីអាយុ៤ឆ្នាំរហូតមកដល់សព្វថ្ងៃនេះ ហើយបើគ្មានមណ្ឌលជួយអនាគតជីវិតកូនរបស់ខ្ញុំមិនដឹងជាល្វង់ដល់កម្រិតណាទេ» នេះជាសម្ដីរបស់អ្នកស្រី ហួន ថាវី វ័យ៥៦ឆ្នាំ សព្វថ្ងៃជាកម្មការិនីកាត់ដេរនៅរោងចក្រមួយកន្លែងក្នុងតំបន់នេះ។

អ្នកស្រីបន្តថា មណ្ឌលលីនដាល់វាសម្រាលទុក្ខព្រួយរបស់គ្រួសារគាត់ ជាកន្លែងដែលផ្តល់សេចក្តីស្រលាញ់ សេចក្តីសុខ និងសង្គ្រោះកូនក្មេងទាំងអស់ ដែលគ្រួសារមានជីវភាពខ្វះខាតបានចូលសាលាសិក្សារៀនសូត្រ មានចំណេះដឹងដើម្បីមានអនាគតភ្លឺស្វាងដូចកូនគេដទៃទៀតបាន។

យុវតី អូន លីហ្សា អាយុ២០ឆ្នាំ បានស្គាល់មណ្ឌលលីនដាល់វាតាំងពីអាយុ១០ឆ្នាំ បានរៀបរាប់ថា មណ្ឌលលីនដាល់វា ជាកន្លែងដែលផ្តល់ជីវិត ផ្តល់ភាពកក់ក្តៅ ផ្តល់សេចក្តីស្រលាញ់

> មណ្ឌលលីនដាល់វាបានជួយឱ្យកូនរបស់ខ្ញុំចូលសាលា ទទួលការសិក្សារៀនសូត្រតាំងពីអាយុ៤ឆ្នាំរហូតមកដល់សព្វថ្ងៃនេះ ហើយបើគ្មានមណ្ឌលជួយអនាគតជីវិតកូនរបស់ខ្ញុំមិនដឹងជាល្វង់ដល់កម្រិតណាទេ

ការមើលថែទាំយ៉ាងកក់ក្តៅពីក្រុមគ្រួសារដូនជីបុត្រីមេត្តាករុណា។

លីហ្សាតែងតែទទួលបានសម្លៀកបំពាក់គ្រឿងឧបភោគ សម្ភារសិក្សា និងថវិកាមួយចំនួនដែរ។

នាងបន្តទៀតថា រូបនាងបានក្លាយជាមនុស្សថ្មីម្នាក់ ដោយមានភាពក្លាហាន មានចំណេះដឹងហ៊ានធ្វើការងារសង្គមនិងមានការងារធ្វើ ដើម្បីជួយដល់បន្ទុកឪពុកម្តាយ ទៀតផង។

មណ្ឌលលីនដាល់វា ទទួលកុមារចាប់ពីអាយុ៤ឆ្នាំឡើងទៅ ដោយផ្តល់ការថែទាំ ផ្តល់អាហាររូបត្ថម្ភ និងមានកម្មវិធីមេត្តេយ្យសិក្សា កម្មវិធីអក្ខរកម្មសម្រាប់កុមារដែលមិនអាចទៅសាលារដ្ឋបាន ផ្តល់អាហាររូបករណ៍ដល់កុមារក្រីក្រនៅថ្នាក់ធម្យមសិក្សានិងឧត្តមសិក្សា។

ដូនជីប្រធានមណ្ឌលឲ្យដឹងថា ក្នុងកុមារម្នាក់មណ្ឌលឲ្យបង់ប្រាក់វិភាគទាន ១៥០០០៛ក្នុងមួយខែ ប្រសិនបើឪពុកម្តាយគ្មានលទ្ធភាពជាអ្នករើសអេតចាយ និងជាកម្មកររើសសំរាម មណ្ឌលផល់សេវាឲ្យឥតគិតថ្លៃ។

ដូនជីជូលី បន្ថែមថា កន្លងមកមានកុមារប្រមាណជា១៥០នាក់ដែលបញ្ចប់ការសិក្សានៅមណ្ឌលហើយត្រូវបានចុះឈ្មោះចូលរៀននៅសាលារដ្ឋ៕





# លោកអភិបាលហង្សលី៖ ចូរធ្វើជាថ្មនាំការសង្គ្រោះដល់អ្នកដទៃ



*អត្ថបទ៖ ម៉េង ភីឡុង*

ក្រោយពេលតុអសនៈក្នុងព្រះវិហារព្រះយេស៊ូដែលមានព្រះជន្មរស់ឡើងវិញនៃព្រះសហគមន៍ចម្លាក់ បានឆេះកាលពីពេលកន្លងទៅ ព្រះសហគមន៍នេះបានរៀបចំតុសក្ការៈថ្មី និងដាក់ឲ្យប្រើប្រាស់ក្រោមអធិបតីភាពរបស់លោកអភិបាលសិលា សួន ហង្សលី អភិបាលព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម កាលពីថ្ងៃទី២៦ ខែសីហា កន្លងទៅ ដោយមានគ្រីស្តបរិស័ទចូលរួម ជិត១០០នាក់។



ក្នុងធម្មទេសនា លោកអភិបាលហង្សលី មានប្រសាសន៍ថា តុសក្ការៈថ្មីនេះធ្វើអំពីថ្ម គឺដើម្បីព្រះយេស៊ូគង់នៅជាមួយ ដើម្បីយើងទទួលពរពីព្រះអង្គ តែសំខាន់ជាងនេះទៅទៀត គឺព្រះយេស៊ូជាថ្មដែលមានជីវិត។ គឺយើងទាំងអស់គ្នាជាគ្រីស្តបរិស័ទជាថ្មដែលមានជីវិត ជាថ្មដែលត្រូវសង់ជាតុសក្ការៈពិតប្រាកដ ហើយតាមរយៈយើង អ្នកដទៃអាចទទួលព្រះពរនិងការសង្គ្រោះ ជាពិសេសអ្នកដែលរស់នៅក្នុងភូមិចម្លាក់នេះ។

លោកអភិបាលបន្ថែម «ព្រះយេស៊ូបានត្រាស់ហៅលោកសិលាទៅជាថ្ម ហើយថ្ងៃនេះ ព្រះអង្គត្រាស់ហៅយើងឲ្យទៅជាថ្មដែរ ដើម្បីឲ្យយើងសាងសង់ព្រះវិហារដែលមានប្រយោជន៍សម្រាប់ពិភពលោកបច្ចុប្បន្ន ដែលណែនាំឲ្យពិភពលោកបច្ចុប្បន្នទទួលការសង្គ្រោះមកពីព្រះជាម្ចាស់។»

លោកអភិបាលបានបន្តទៀតថា ជាមួយតុសក្ការៈនៅព្រះសហគមន៍ចំឡាក់នេះមានលក្ខណៈពិសេស ដោយសារយើងមានអដ្ឋិធាតុរបស់ អ្នកមានសុភមង្គល កាឡូ អាគីទីស ដើម្បីឲ្យបងប្អូនមកអធិដ្ឋាន និងចូលរួមអភិបូជា បានទទួលព្រះពរពីព្រះជាម្ចាស់និងក្លាយជាគ្រីស្តបរិស័ទដ៏ល្អ ហើយមានសេចក្តីស្រឡាញ់ចំពោះព្រះកាយព្រះគ្រីស្ត និងចំពោះបងប្អូនឯទៀតៗនៅក្នុងភូមិចម្លាក់នេះផង។

តុសក្ការៈចាស់ធ្វើអំពីឈើបានឆេះទាំងស្រុងដោយមិនដឹងមូលហេតុ កាលពីថ្ងៃ១៨ ខែឧសភា ឆ្នាំ២០២៣។ តុសក្ការៈថ្មីនេះបានបញ្ចុះសក់ចំនួន៣សរសៃរបស់អ្នកមានសុភមង្គល កាឡូ អាគីទីស ដែលសម្តេចប៉ាប ប្រកាសជាអ្នកមានសុភមង្គល កាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០២០ នៅទីក្រុងអាស៊ីស៊ី ប្រទេស

> ព្រះយេស៊ូបានត្រាស់ហៅលោកសិលាទៅជាថ្ម ហើយថ្ងៃនេះ ព្រះអង្គត្រាស់ហៅយើងឲ្យទៅជាថ្មដែរ ដើម្បីឲ្យយើងសាងសង់ព្រះវិហារដែលមានប្រយោជន៍សម្រាប់ពិភពលោកបច្ចុប្បន្ន ដែលណែនាំឲ្យពិភពលោកបច្ចុប្បន្នទទួលការសង្គ្រោះមកពីព្រះជាម្ចាស់

អ៊ីតា។ កាឡូ អាគីទីស កើតនៅថ្ងៃទី០៣ ខែឧសភា ឆ្នាំ១៩៩១ នៅប្រទេសអ៊ីតាលី។ លោកជាយុវជនម្នាក់ដែលមានសេចក្តីស្រឡាញ់យ៉ាងខ្លាំងចំពោះព្រះកាយព្រះគ្រីស្ត។ គាត់បានចូលរួមអភិបូជាជារៀងរាល់ថ្ងៃចាប់តាំងពីអាយុ ៧ឆ្នាំ និងចំណាយពេលជារៀងរាល់ថ្ងៃដើម្បីតាំងព្រះកាយ។ គាត់ជឿថា «យើងទទួលព្រះកាយព្រះគ្រីស្ត នោះយើងនឹងកាន់តែដូចជាព្រះយេស៊ូ»។ គាត់បានទទួលមរណភាពនៅឆ្នាំ២០០៦ ដោយជម្ងឺមហារីកឈាម។

ព្រះសហគមន៍កាតូលិកចម្លាក់ ស្ថិតនៅភូមិចំឡាក់ ឃុំចក ស្រុកអូរាំងឪ ខេត្តត្បូងឃ្មុំ មានចម្ងាយ៤០គីឡូ ពីក្រុងកំពង់ចាម និងមានចម្ងាយ១២២គីឡូម៉ែត្រពីរាជធានីភ្នំពេញ។ ព្រះសហគមន៍នេះ បានកសាងនៅឆ្នាំ២០០៥ ដោយលោកបូជាចារ្យ ហ្វ្រង់ស្វ័រ ប៉ុងសូដ៍។ សព្វថ្ងៃមានគ្រីស្តបរិស័ទប្រមាណ ៣០នាក់ ជាអ្នកធ្វើស្រែចម្ការ។ ព្រះសហគមន៍កាតូលិកនេះ សកម្មភាពដូចជាសាលាមត្តេយ្យ មណ្ឌលទទួលសិស្សថ្នាក់មធ្យមសិក្សា និងកម្មវិធីអប់រំជំនឿជាដើម៕

# លោកដាម៉ូ ក្លាយជាបព្វជិតសហជីវិនព្រះយេស៊ូដំបូងនៅកម្ពុជា

*អត្ថបទ៖ កែវ កញ្ញា*

គ្រីស្តបរិស័ទជាង២០០០នាក់អាជ្ញាធរដែនដី និងព្រះសង្ឃជាច្រើនអង្គបានចូលរួមពិធីអគ្គសញ្ញាតែងតាំងជាបូជាចារ្យរបស់លោកម៉ាតាំង ជួរ ដាម៉ូ ក្នុងក្រុមបព្វជិតសហជីវិនព្រះយេស៊ូ ក្រោមអធិបតីភាពរបស់លោកអភិបាលអូលីវីយេ ជ្មីតហាស្លេ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ រួមជាមួយលោកអភិបាលនិងបូជាចារ្យជាច្រើនអង្គ។



លោកអភិបាលអធិបតី មានប្រសាសន៍ក្នុងធម្មទេសនាថា ថ្ងៃនេះ ជាអំណរសប្បាយរបស់ក្រុមសហជីវិនព្រះយេស៊ូ និងព្រះសហគមន៍កាតូលិកនៅកម្ពុជាដែលជាម្ចាស់ផ្ទះនៅថ្ងៃនេះទទួលស្វាគមន៍លោកដាម៉ូក្នុងក្រុមបូជាចារ្យ។

«សម្រាប់ព្រះសហគមន៍យើងខ្ញុំ ទទួលបូជាចារ្យថ្មីមួយរូប មិនមែនរឿងធម្មតាទេ។ ជារឿងដែលយើងមានម្តងៗ។» លោកអភិបាលបន្ថែម។

ព្រះសហគមន៍ប្រទេសកម្ពុជា កម្រមានពិធីតែងតាំងបូជាចារ្យណាស់ ក្រោយពេលដែលកម្ពុជាបានធ្លាក់ក្នុងភ្លើងសង្គ្រាមរបបអាវខ្មៅ។ បច្ចុប្បន្ននេះ មានបូជាចារ្យជាតិខ្មែរជាបូជាចារ្យភូមិភាគ ចំនួន១០រូបក្នុងចំណោមសាសនាទូត និងបព្វជិតជាង១០០នាក់ដែលកំពុងបម្រើការងារនៅក្នុងភូមិភាគទាំងបីដែលមានព្រះសហគមន៍ជាង១០០កន្លែង។

លោកអភិបាលបន្ថែមថា នៅពេលនេះ លោកដាម៉ូនឹងក្លាយជាអ្នកបម្រើរបស់ព្រះយេស៊ូ ដោយដើរតាមព្រះអង្គ និងជាអ្នកបម្រើក្នុងក្រុមសហជីវិនព្រះយេស៊ូដែលបានស្រឡាញ់ព្រះសហគមន៍កម្ពុជាជាពិសេស។

លោកអភិបាលបានដាស់តឿននូវមុខងារជាអ្នកបម្រើ ៣ចំណុចដល់លោកបូជាចារ្យថ្មីគឺ ទី១ ជាអ្នកបម្រើព្រះបន្ទូលដំណឹងល្អរបស់ព្រះជាម្ចាស់ដែលយើងត្រូវតែប្រកាស និងត្រូវណែនាំដល់កុមារ និងយុវជន ដល់មនុស្សគ្មានចំណេះដឹង និងត្រូវប្រកាសគ្រប់កាលៈទេសៈនៃជីវិត។

រីឯទី២ ជាអ្នកបម្រើតាមផ្លូវវិញ្ញាណ ដើម្បីជួយឲ្យព្រលឹងរបស់មនុស្សលោកអាចចូលយ៉ាងជ្រៅទៅក្នុងអាថ៌កំបាំងនៃជីវិតផ្ទាល់ខ្លួន ដើម្បីទទួលអគ្គសញ្ញានានា ដើម្បីចិញ្ចឹមផ្លូវវិញ្ញាណឲ្យរីកចម្រើននិងជាប់ជាមួយព្រះជាម្ចាស់ជានិច្ច។

និងទី៣ ជាអ្នកបម្រើព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់គឺត្រូវជួយសម្រុះសម្រួល ជួយអ្នកក្រីក្រ អ្នកជំងឺ និងទណ្ឌិត ជួយអ្នកតូចតាចដែលគេបានបោះបង់ចោល បងប្អូនគ្រីស្តបរិស័ទ អ្នកស្វែងរកព្រះជាម្ចាស់ និងបម្រើយុត្តិធម៌នៅក្នុងសង្គម។

ក្នុងនោះដែរ លោកអភិបាលអូលីវីយេ បានជំរុញឲ្យគ្រីស្តបរិស័ទគិតអំពីតួនាទីជាអ្នកបម្រើនេះដែរ។ លោកបន្ថែមថា ឲ្យយើងទៅជាអ្នកបម្រើក្នុងការប្រណីសន្តោសដោយហ៊ានសម្រុះសម្រួលគ្រប់កាលៈទេសៈនៃជីវិត ឲ្យយើងទៅជាអ្នកបម្រើសុខសន្តិភាពនៅកន្លែងសង្គ្រាមទាស់ទែងគ្នា ប្រណែន ស្អប់ដើម្បីឲ្យក្តីស្រឡាញ់របស់ព្រះជាម្ចាស់ផុសចេញមក និងឲ្យយើងទៅជាអ្នកបម្រើដោយលុតជង្គង់នៅក្បែរបងប្អូនដែលតូចតាចគ្រប់កាលៈទេសៈ ដែលកំពុងរង់ចាំភាពញញឹម សេចក្តីស្រឡាញ់ ថ្នាក់ថ្នម និងលើកទឹកចិត្ត។

លោកម៉ាតាំង ជួរ ដាម៉ូ ជាបូជាចារ្យខ្មែរដំបូងបង្អស់ដែលបានចូលបួសក្នុងក្រុមសហជីវិនព្រះយេស៊ូក្នុងប្រទេសកម្ពុជា ដែលត្រូវបានតែងតាំងកាលពីថ្ងៃទី១៩ ខែសីហាកន្លងទៅនៅព្រះវិហារព្រះជាម្ចាស់លើកព្រះនាងម៉ារីឡើងស្ថានបរមសុខ (ពេទ្យឃាយជី) ក្នុងក្រុងបាត់ដំបង ខេត្តបាត់ដំបង ស្ថិតក្នុងភាគខាងលិចនៃប្រទេសកម្ពុជា ប្រមាណជា២៩១គីឡូម៉ែត្រពីរាជធានីភ្នំពេញ។

ក្នុងពេលដែលប្រជាជនកម្ពុជាបានភៀសខ្លួនទៅជំរំខ្មែរ-ថៃ សមាជិកនៃក្រុមសហជីវិនព្រះយេស៊ូបានជួយដល់ប្រជាជនខ្មែរមួយចំនួនក្នុងជំរំ ហើយពេលមាតុភូមិនិវត្តន៍ ពួកលោកបានមកបម្រើការក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ១៩៩០។ បេសកកម្មរបស់ក្រុមនេះ គឺជួយដល់ជនក្រីក្រជាពិសេសជនមានពិការភាព។

លោកបូជាចារ្យ ស៊ីម៉ូន អូ ឆាង ជាប្រធានក្រុមសហជីវិនព្រះយេស៊ូនៅប្រទេសកម្ពុជា មានប្រសាសន៍ថា ថ្ងៃនេះ គាត់មានអំណរសប្បាយខ្លាំងណាស់។ «ខ្ញុំជាបេសកជនមកពីប្រទេសផ្សេង បើសិនយើងឃើញថា កូនខ្មែរអាចបន្តបេសកកម្មនេះ និងប្រកាសដំណឹងល្អតាមរយៈភាសារបស់គាត់ ជាការអស្ចារ្យ ហើយខ្ញុំរំភើបមែនទែន។»

បច្ចុប្បន្នក្រុមសហជីវិនព្រះយេស៊ូ មានយុវ៉ែនខ្មែរ៣រូបផ្សេងទៀតដែលកំពុងរៀនបួស។

អ្នកស្រី តេរេសា សួន ប៊ុនថា ជាម្តាយរបស់លោកបូជាចារ្យថ្មី មានប្រសាសន៍ថា គោលដៅជាបូជាចារ្យរបស់លោកដាម៉ូកើតឡើងនៅអាយុ៨ឆ្នាំមកម្ល៉េះ។

«ខ្ញុំប្រាប់គាត់ថា កូនអត់ចេះធ្វើអីផង បោកខោអាវមិនទាំងស្អាតផង ទៅបម្រើអ្នកណាបាន បើកូនចង់ទៅអីចឹង ត្រូវចេះធ្វើអីខ្លួនឯងកុំឲ្យម៉ាក់ពិបាក។ ដល់ពេលហ្នឹងកូនចាប់ផ្តើមជួយខ្លួនបាន។»អ្នកស្រីបញ្ជាក់។

អ្នកស្រីប៊ុនថា បានសារភាពថា ពេលរៀននៅមហាវិទ្យាល័យ អ្នកស្រីបានបង្វៀងកូនឲ្យនៅឆ្ងាយពីព្រះសហគមន៍ព្រោះគាត់យល់ថា ជារឿងកូនក្មេងប៉ុណ្ណោះ។ ទោះបីយ៉ាងនេះក្តី យុវ៉ែនដាម៉ូ បានខិតខំសុំលោកបូជាចារ្យទទួលខុសត្រូវមណ្ឌលនិស្សិតកាតូលិក ឲ្យទទួលគាត់ស្នាក់នៅ និងរៀននៅទីនោះ។

«ពេលកូនបានចូលមណ្ឌលនិស្សិត កូនចាប់ផ្តើមរឹងប៉ឹង» ហើយប្តីរបស់គាត់តែងប្រាប់គាត់ថា ពួកយើងអាចចិញ្ចឹមកូនតែរូបកាយ និងឲ្យគេរៀនសូត្រចេះដឹងតែមិនអាចសម្រេចអនាគតឲ្យគេបានឡើយ ហើយបួសនេះក៏មិនមែនជារឿងអាក្រក់ដែរ «កូនទៅធ្វើអ្នកសង្គ្រោះ ជាអំពើល្អមួយជួយមនុស្សទូទៅនៅលើផែនដី។» អ្នកស្រីបញ្ជាក់។

ចាប់ពីពេលនោះមកអ្នកស្រី បានលើកទឹកចិត្តនិងអធិដ្ឋានសម្រាប់កូនប្រុសរបស់គាត់រូបនេះ ឲ្យទទួលបាននូវអ្វីដែលគាត់ប្រាថ្នាក្នុងជីវិតរហូតមកដល់ថ្ងៃនេះ។

និយាយដោយអួលដើមក យកដៃជូតទឹកភ្នែកផង ស្ត្រីជាម្តាយរូបនេះ បន្តថា «សប្បាយឡើងស្រក់ទឹកភ្នែក មិនមែនដោយសារស្តាយកូនទេ តែរំភើប ព្រោះកូនខ្ញុំជាង២០ឆ្នាំទំរាំបានបួស។ កូនត្រូវរៀនលុតដំសព្វគ្រប់បែបយ៉ាង។»

លោកម៉ាតាំង ជួរ ដាម៉ូ អាយុ៣៨ឆ្នាំ កើតនៅខេត្តកំពង់ចាម ជាកូនទី៣ក្នុងចំណោមបងប្អូន៤នាក់។ លោកបញ្ចប់ការសិក្សាបរិញ្ញាបត្រផ្នែកគ្រប់គ្រងធុរកិច្ចក្នុងឆ្នាំ២០០៦ ហើយក្នុងឆ្នាំ២០១២ លោកបានចូលរួមជាសាមណេរក្នុងក្រុមសហជីវិនព្រះយេស៊ូ។ ក្នុងឆ្នាំ២០២២ លោកបានទទួលពិធីតែងតាំងជាឧបដ្ឋាកនៅទីក្រុងម៉ានីលប្រទេសហ្វីលីពីន។

នៅថ្ងៃតែងតាំង លោកបព្វជិត ជួរ ដាម៉ូត្រូវបានប្រកាសចាត់ឲ្យទទួលមុខងារលើការត្រាស់ហៅ និងបម្រើយុវជនសម្រាប់ព្រះសហគមន៍ក្នុងភូមិភាគទាំង៣។

ចំពោះកិច្ចការងារនេះលោកបូជាចារ្យថ្មី បន្ថែមថា គាត់ត្រូវបើកចិត្តទូលាយដើម្បីជួយណែនាំយុវជន ឲ្យបានតាប់ព្រះហឫទ័យព្រះជាម្ចាស់។ ចំពោះគាត់មិនមែនធ្វើការងារសម្រាប់តែការត្រាស់ហៅក្នុងក្រុមសហជីវិនព្រះយេស៊ូ ឬចូលជាអ្នកបួសទេ ព្រោះក្នុងជីវិតរស់នៅរបស់យុវជន គឺត្រូវការអ្នកណែនាំជាពិសេសខាងផ្លូវវិញ្ញាណ។

លោកគ្រោងនឹងចុះសួរសុខទុក្ខយុវជនកាតូលិក បង្កើតទំនាក់ទំនង និងអប់រំផ្លូវវិញ្ញាណដល់ពួកគាត់បន្ថែម ដើម្បីឲ្យពួកគាត់អាចរកឃើញព្រះបំណងរបស់ព្រះជាម្ចាស់ក្នុងជីវិតប្រចាំថ្ងៃ និងជីវិតទៅអនាគត។

លោកអេនរីគេ ហ្វីការេដូ អភិបាលព្រះសហគមន៍ភូមិភាគបាត់ដំបង បានឲ្យដឹងថា គាត់រំភើបដោយបានឃើញយុវជនខ្មែរឆ្លើយតបការត្រាស់ហៅជាបូជាចារ្យ ហើយការចូលរួមពីសំណាក់លោកអភិបាលបូជាចារ្យបព្វជិត-ជិតាអាជ្ញាធរព្រះសង្ឃ និងគ្រីស្តបរិស័ទទាំងបីភូមិភាគជាសញ្ញាមួយថា យើងជួបជុំគ្នាកសាងព្រះរាជ្យរបស់ព្រះជាម្ចាស់។

លោកក៏សង្ឃឹមថា ព្រះសហគមន៍ភូមិភាគបាត់ដំបងនឹងមានយុវជន ចាប់អារម្មណ៍អំពីការត្រាស់ហៅនេះ។ លោកប្រាប់ថា ដើម្បីឲ្យយើងអាចទៅខាងមុខក្នុងជីវិតត្រាស់ហៅ គឺទី១ យើងត្រូវស្តាប់ព្រះជាម្ចាស់ដោយបើកចិត្តដើម្បីអាចប្រព្រឹត្តតាមព្រះហឫទ័យព្រះជាម្ចាស់ ទី២គឺមិនតាមអារម្មណ៍និងចិត្តយើង តែត្រូវលះបង់ច្រើន ដើម្បីប្រយោជន៍រួម គឺព្រះជាម្ចាស់ និងព្រះសហគមន៍។

«ព្រះសហគមន៍ត្រូវការយុវជនយកចិត្តទុកដាក់ស្តាប់ការត្រាស់ហៅពីព្រះជាម្ចាស់ និងបូជាជីវិតសម្រាប់ប្រយោជន៍រួមដូចព្រះយេស៊ូ។» លោកអភិបាលអេនរីគេបញ្ជាក់។

ក្នុងបទសំភាសន៍លោកអភិបាលអូលីវីយេ ឲ្យដឹងថា លោកដាម៉ូ រួមជាមួយព្រះសហគមន៍ភូមិភាគទាំងបី សហការគ្នា ដើម្បីបម្រើព្រះបន្ទូល បម្រើខាងផ្លូវវិញ្ញាណ និងបម្រើអ្នកក្រីក្រ។ «ខ្ញុំសង្ឃឹម ដាម៉ូដែលជាបូជាចារ្យJesuit (សហជីវិនព្រះយេស៊ូ) ដែលជាខ្មែរដំបូង អាចចូលយ៉ាងជ្រៅនៅក្នុងព្រះសហគមន៍និងវប្បធម៌ ដើម្បីជួយឲ្យព្រះសហគមន៍ផង និងប្រទេសកម្ពុជាផង អាចផ្តល់សក្ខីភាពអំពីជីវិតរបស់ព្រះយេស៊ូ និងឲ្យយើងបង្កើតមិត្តសម្លាញ់របស់ព្រះគ្រីស្តយ៉ាងច្រើន។»

លោកអភិបាលក៏សូមអធិដ្ឋានសម្រាប់យុវជន ឲ្យរកឃើញការត្រាស់ហៅរបស់ខ្លួនក្នុងពិធីតែងតាំងបូជាចារ្យម៉ាតាំង ជួរ ដាម៉ូនេះ។

ក្នុងពិធីនេះដែរ សម្តេចប៉ាបហ្វ្រង់ស៊ីស្លូ ក៏បានផ្ញើសារលិខិតចូលរួមអបអរសាទរដល់លោកបូជាចារ្យ ម៉ាតាំង ជួរ ដាម៉ូផងដែរ ដោយទ្រង់បានលើកទឹកចិត្តនិងស្វាគមន៍ការចូលក្នុងក្រុមបូជាចារ្យរបស់ព្រះយេស៊ូគ្រីស្ត៕





# អាវបូជាចារ្យនាំឱ្យលោក វី សំណាង នឹងក្លាយជាបូជាចារ្យ

*អត្ថបទ៖ ស៊ីអេសស៊ី*

អាវបំពង់សវែងរបស់បូជាចារ្យកាតូលិក បានធ្វើឲ្យកុមារម្នាក់ចាប់អារម្មណ៍ និងចង់ពាក់អាវនេះក្នុងមុខងារដូចគ្នាដែរ។ ក្តីសុបិន្តរបស់កុមាររូបនេះ បានចម្រើនឡើងនិងខិតទៅជិតជីវិតជាអ្នកបួសដើម្បីបម្រើគ្រីស្តបរិស័ទក្នុងឋានៈជាគង្វាលនាពេលឆាប់ៗនេះ។



«នេះប្រហែលជាការត្រាស់ហៅទី១ ដែលព្រះជាម្ចាស់ដាក់ក្នុងចិត្តរបស់ខ្ញុំ ហើយខ្ញុំចាប់អារម្មណ៍ស្រឡាញ់អាវបូជាចារ្យ។» នេះជាប្រសាសន៍របស់លោកវីសំណាងដែលជាឧបដ្ឋាកបច្ចុប្បន្នកំពុងបម្រើការងារនៅព្រះវិហារព្រះកុមារយេស៊ូបឹងទំពុន ស្ថិតក្នុងមណ្ឌលសកម្មភាពភ្នំពេញខាងត្បូង នារាជធានីភ្នំពេញ។

លោកចាប់ផ្តើមឈ្វេងយល់អំពីការត្រាស់ហៅក្នុងវ័យ១០ឆ្នាំ ដោយចាប់អារម្មណ៍ទៅលើសំលៀកបំពាក់របស់បូជាចារ្យ ក្នុងពេលថ្វាយអភិបូជារាល់ពេលដែលលោកចូលក្នុងព្រះវិហារ។

«ខ្ញុំអត់ដឹងថាត្រូវក្លាយជាបូជាចារ្យយ៉ាងណា ខ្ញុំអត់ដឹងទេ តែសំខាន់ខ្ញុំចាប់អារម្មណ៍អាវតែប៉ុណ្ណឹង។»លោកបន្ថែម។

លោកវីសំណាង ជាកូនចៅគ្រីស្តបរិស័ទដែលតែងតែទៅព្រះវិហារតួតាំងជាប្រចាំ ហើយទទួលការអប់រំជំនឿក្នុងព្រះវិហារ។ ពេលចម្រើនវ័យសំណាងបានស្នើសុំឪពុកម្តាយដើម្បីចូលឈ្វេងយល់អំពីការត្រាស់ហៅប៉ុន្តែត្រូវបានឪពុកបដិសេធ ដោយដាក់លក្ខខណ្ឌថា «បើមានប្អូនទាល់កូនប្រុសទៀតបានឱ្យទៅ បើកូនស្រីមិនឱ្យទៅទេ។»

ដោយសារជាកូនទោលក្នុងគ្រួសារ សំណាងមិនហ៊ានប្រកែកនឹងយោបល់របស់ឪពុកខ្លួនទេ ប៉ុន្តែគាត់បានខិតខំសិក្សារៀនសូត្រ ស្វះស្វែងរកកន្លែងបន្តការសិក្សារបស់ខ្លួន។

ការអស្ចារ្យបានកើតឡើង ទោះបីជាម្តាយរបស់គាត់មានបញ្ហាសុខភាពមិនអាចមានកូនបានក៏ដោយ ព្រះជាម្ចាស់បានប្រោះប្រទានឲ្យគ្រួសារនេះមានកូនប្រុសម្នាក់ទៀត។ ក្តីសុបិន្តចង់ក្លាយជាបូជាចារ្យបានដុះពន្លកកើតចេញជាត្រួយបន្តិចម្តងៗ។

«រហូតមកដល់ឥឡូវ ខ្ញុំគិតថានេះជាអ្វីមួយដែលព្រះជាម្ចាស់បានធ្វើការ តាមរយៈការអស្ចារ្យ ហួសពីការគិតរបស់មនុស្សដែរ។» លោកសំណាងបញ្ជាក់។

បន្ទាប់ពីបានទទួលការអនុញ្ញាត លោកបានខិតខំសិក្សារៀនសូត្ររហូតចប់មធ្យមសិក្សា ហើយបន្តរៀនខាងបច្ចេកទេសកុំព្យូទ័រនៅសាលាបច្ចេកទេសដុនបូស្កូភ្នំពេញ ដើម្បីបន្តឈ្វេងយល់ពីការត្រាស់ហៅនេះ។

លោកឧបដ្ឋាករូបនេះបានបន្ថែមថា លោកចង់រស់នៅជាមួយអ្នកភូមិ សួរសុខទុក្ខគេរស់នៅជាមួយព្រះសហគមន៍ តែមិនមែនជារបៀបរស់នៅក្នុងក្រុមបព្វជិតនោះឡើយ។ ដោយឃើញចំណូលចិត្តបែបនេះ លោកបូជាចារ្យផ្លូវវិញ្ញាណរបស់លោកបានណែនាំលោកចូលទៅវិទ្យាល័យសន្តយ៉ូហានម៉ារីវីយ៉ាំណែរក្នុងឆ្នាំ២០១៥។

«ពេលចូលទៅវិទ្យាល័យ ចម្លើយដែលខ្ញុំទទួលបានគឺសេចក្តីសុខសាន្ត និងអំណរសប្បាយ។ ... ពេលខ្ញុំនិយាយពីសេចក្តីសុខសាន្ត និងអំណរសប្បាយមិនមែនមានន័យថា យើងក្លាយជាបូជាចារ្យយើងអត់មានទុក្ខលំបាក។សេចក្តីសុខសាន្តនោះគឺណែនាំឱ្យមានសង្ឃឹមថា ទោះបីមានទុក្ខលំបាក ខ្ញុំរកឃើញវត្តមានរបស់ព្រះជាម្ចាស់នៅក្នុងចិត្តរបស់ខ្ញុំ។» លោកឧបដ្ឋាកបញ្ជាក់។

នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៨ លោកវីសំណាង បានទទួលមុខងារជានិស្សិតទេវវិទ្យាល័យផ្លូវការ។ ហើយនៅឆ្នាំបន្តបន្ទាប់ លោកបានទទួលមុខងារជា អ្នកប្រកាសព្រះបន្ទូល អ្នកបម្រើតុសក្ការៈ និងនៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២២ លោកទទួលអគ្គសញ្ញាតែងតាំងជាលោកឧបដ្ឋាក។

ក្នុងឋានៈជានិស្សិតទេវវិទ្យាល័យជិត១០ឆ្នាំមកនេះ លោកបូជាចារ្យនាយកទេវវិទ្យាល័យបានចាត់លោកឲ្យទៅកន្លែងជាច្រើន ដើម្បីបម្រើនិងចូលទៅក្នុងជីវិតរស់នៅរបស់បងប្អូនគ្រីស្តបរិស័ទ។

លោកសំណាងបញ្ជាក់ថា«ខ្ញុំគិតថាបូជាចារ្យមិនមែនជាគោលដៅចុងក្រោយរបស់ខ្ញុំទេ គោលដៅរបស់ខ្ញុំគឺព្រះយេស៊ូ ប៉ុន្តែជីវិតជាបូជាចារ្យជាផ្លូវមួយដែលនាំឱ្យខ្ញុំជិតស្និទ្ធជាមួយព្រះអង្គ ហើយបម្រើបងប្អូន។»

អនាគតបូជាចារ្យរូបនេះ បន្ថែមថា ការត្រាស់ហៅរបស់ព្រះជាម្ចាស់ជារឿងសាមញ្ញ តាមរយៈទីសម្គាល់តូចតាច។ ដូច្នេះយុវជនមិនគួរភ័យខ្លាចចំពោះការត្រាស់ហៅរបស់ព្រះជាម្ចាស់នោះឡើយ។

លោកបានផ្ញើសារសម្រាប់យុវជនកាតូលិកថា «នៅទេវវិទ្យាល័យខ្ញុំគិតថា ជាពេលវេលាគ្រប់ល្មមដើម្បីរិះគិតថា ព្រះជាម្ចាស់ចង់ឱ្យខ្ញុំធ្វើអ្វី? ប្រសិនបើព្រះជាម្ចាស់ចង់ឱ្យខ្ញុំរៀបការ យើងអាចនៅទេវវិទ្យាល័យ៣ ៤ ៥ ឆ្នាំ រហូតដល់យើងច្បាស់ថា ព្រះជាម្ចាស់ចង់ឱ្យយើងរៀបការ យើងអាចចេញបាន ហើយរៀបការ។»

លោកឧបដ្ឋាកយ៉ូហានបាទីស្ត វី សំណាង កើតនៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ១៩៩៤ នៅភូមិដើមស្លែង សង្កាត់ច្បារអំពៅ២ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ក្នុងក្រុមគ្រួសារគ្រីស្តបរិស័ទនៅព្រះសហគមន៍តួតាំង។ លោកទទួលអគ្គសញ្ញាជ្រមុជទឹក នៅថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៩៩៤ អគ្គសញ្ញាលាបថ្វាសនៅថ្ងៃទី១ខែមិថុនា ឆ្នាំ២០០៨។ ក្នុងពេលឆាប់ៗនេះ លោក នឹងទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យពីលោកអភិបាល អូលីវីយេ ជ្មីតហាស្លេ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ នៅមជ្ឈមណ្ឌលព្រះសហគមន៍កាតូលិកភ្នំពេញថ្មី នាថ្ងៃទី២៣ ខែកញ្ញា ខាងមុខនេះ៕

# លោក ប៉ូល វិន កាន់៖ អំណរសប្បាយបូជាចារ្យ គឺបាននៅជិតព្រះជាម្ចាស់



*អត្ថបទ៖ សួន ស្រីហួចដាលីស*

លោកបូជាចារ្យជាបុគ្គលមួយរូបសំខាន់សម្រាប់ព្រះសហគមន៍កាតូលិក គឺត្រូវថ្វាយសក្ការបូជាប្រចាំថ្ងៃ ជាតំណាងព្រះយេស៊ូគ្រីស្ត និងជាអ្នកណែនាំគ្រីស្តបរិស័ទឲ្យស្គាល់មាគ៌ារបស់ព្រះជាម្ចាស់។

«សម្រាប់ខ្ញុំ ជីវិតជាបូជាចារ្យមានអត្ថន័យ មានតម្លៃ ដោយសារបូជាចារ្យជួយច្រើន មិនត្រឹមតែជួយផ្នែករូបកាយ តែជួយទាំងផ្លូវវិញ្ញាណគ្រីស្តបរិស័ទ។ នេះខ្ញុំចាប់អារម្មណ៍មុខងារជាបូជាចារ្យណាស់»។ នេះជាប្រសាសន៍របស់លោកប៉ូល វិន កាន់ ជាឧបដ្ឋាក។

យ៉ាងណាមិញ ជីវិតជាអ្នកបួសនេះ យុវជនមិនសូវចាប់អារម្មណ៍ប៉ុន្មានទេ ដោយសារតែសម្ភារៈបច្ចេកទេស និងភាពសប្បាយរីករាយបែបលោកីយ៍ទាក់ទាញចិត្តរបស់ពួកគេ។ បច្ចុប្បន្ន ការត្រាស់ហៅរបស់ព្រះជាម្ចាស់ចំពោះជីវិតជាអ្នកបួសក្នុងចំណោមគ្រីស្តបរិស័ទនៅកម្ពុជាមានតិចតួចនៅឡើយ ដោយមានជនជាតិខ្មែរគឺលោកបូជាចារ្យចំនួន១១អង្គ និងបព្វជិតមួយរូប និងបព្វជិតា ជិត ២០នាក់ប៉ុណ្ណោះ ក្នុងចំណោមសាសនទូត និងបព្វ-ជិតាជាង ១៥០នាក់ ដែលកំពុងបម្រើការងារនៅក្នុងប្រទេសកម្ពុជា។

លោកប៉ូលវិន កាន់ ដែលជាយុវជន បានមើលឃើញតម្រូវការនេះ ហើយចាប់អារម្មណ៍ចង់បន្តបេសកកម្មជាសាសនទូតសម្រាប់ព្រះជាម្ចាស់ ដោយ«ស្រឡាញ់និងបម្រើ» ព្រះសហគមន៍និងព្រះជាម្ចាស់។

ពេលនេះ លោកប៉ូល វិន កាន់ ជាឧបដ្ឋាកមួយរូប ដែលជាជំហានចុងក្រោយនៃជីវិតជានិស្សិតទេវវិទ្យាល័យ ហើយនឹងត្រូវតែងតាំងជាបូជាចារ្យ នាពេលខាងមុខនេះ។ លោកមានប្រសាសន៍ថា «ក្នុងព្រះសហគមន៍ប្រទេសកម្ពុជាយើងតូច មានប្រជាជនជាច្រើនដែលមិនទាន់ស្គាល់ព្រះយេស៊ូ និងមុខងាររបស់លោកបូជាចារ្យគឺប្រកាសដំណឹងល្អ។ ដូច្នេះខ្ញុំស្រឡាញ់ជីវិតជាបូជាចារ្យដោយអាចធ្វើអត្តសញ្ញាសម្រាប់គេ និងអាចធ្វើជាលោកខាងវិញ្ញាណដែលដូចជាគ្រូពេទ្យចិត្តសាស្ត្រម្យ៉ាងជួយបងប្អូនទាំងផ្លូវចិត្តនិងផ្លូវវិញ្ញាណ»។

បូជាចារ្យជាការត្រាស់ហៅមួយយ៉ាងពិសេសពីព្រះជាម្ចាស់ លោកកាន់បានចាប់អារម្មណ៍អំពីរឿងនេះក្នុងថ្នាក់អប់រំជំនឿ តាំងពីវ័យកុមារ ពោលគឺពេលលោកកំពុងរៀននៅបឋមសិក្សានៅឡើយ។ លោកឧបដ្ឋាកដែលកំពុងបម្រើការងារនៅព្រះសហគមន៍កោះកុងក្រោមការណែនាំរបស់លោកបូជាចារ្យ យ៉ាំងលូកា តាវ៉ូឡា ជាបូជាចារ្យប្រធានទទួលខុសត្រូវតំបន់កំពង់សោមបានឲ្យដឹងថា ទំរាំមកដល់ថ្ងៃនេះ គឺវាពិបាកណាស់សម្រាប់គាត់ ដោយត្រូវឆ្លងកាត់នូវរឿងរ៉ាវមួយចំនួន ទាំងការសិក្សា និងបញ្ហាជីវភាពគ្រួសារ ហើយបងប្អូនរបស់លោកក៏គ្មានចំណូលអ្វីធំដុំដែរ។

«ខ្ញុំដឹងត្រឹមថាខ្ញុំចង់ធ្វើជាបូជាចារ្យដោយសារមានគំរូនៅមុខខ្ញុំ។ រាល់ថ្ងៃចូលអភិបូជា។ ខ្ញុំស្រឡាញ់កាយវិការរបស់លោកបូជាចារ្យ ចឹងខ្ញុំចង់ធ្វើតាម។» លោកបន្ថែម។

លោកឧបដ្ឋាកប៉ូល វិនកាន់ កើតនៅថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៩២ នៅភូមិចំប៉ា សង្កាត់ក្បាលកោះ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។ លោកកើតនៅក្នុងក្រុមគ្រួសារកាតូលិកតាំងពីដូនតា ដោយមានបងប្អូនទាំងអស់៦នាក់ ប្រុស៤នាក់ និងស្រី២ ហើយលោកជាកូនទី៥ក្នុងគ្រួសារ។ ឪពុកម្តាយរបស់លោកប្រកបមុខរបរជាអ្នកនេសាទនិងជាអ្នកលក់ដូរត្រីនៅផ្សារ។

លោកកាន់ឲ្យដឹងថា នៅពេលលោកប្រាប់បំណងចង់បួសរបស់លោកដល់ឪពុកម្តាយ «ពួកគាត់សប្បាយចិត្តមិនមានអីប្រៀបធៀបបាន នេះជាអំណរសប្បាយរបស់ពួកគាត់ និងពួកគាត់ជំរុញឱ្យទៅមុខហើយ ទៅទៀតកុំបកមកក្រោយ ទៅបម្រើព្រះជាម្ចាស់អស់មួយជីវិតទៅ»។

ដោយសារការគាំទ្រនេះ យុវជនកាន់បានឆ្លងផុតដំណាក់កាលលំបាកជាច្រើន ហើយបានបន្តការសិក្សារបស់ខ្លួនដោយទទួលអាហារូបករណ៍ពីសាលាដុនបូស្កូរហូតចប់មធ្យមសិក្សា និងបន្តចូលរៀននៅទេវវិទ្យាល័យសន្តយ៉ូហានម៉ារីយ៉ាណែរក្នុងឆ្នាំ២០១៥។

«ប៉ាខ្ញុំនិយាយថា គាត់គ្មានអ្វីឱ្យកូនទេ មានតែពាក្យលើកទឹកចិត្តឱ្យកូនខិតខំរៀននិងដើរតាមបម្រើព្រះជាម្ចាស់អស់មួយជីវិត និងគាត់រង់ចាំថ្ងៃតែមួយ គឺថ្ងៃដែលខ្ញុំធ្វើជាបូជាចារ្យហើយត្រលប់ទៅវិញធ្វើបុណ្យសពឱ្យគាត់គឺគាត់សប្បាយចិត្តដែរ»។ លោកឧបដ្ឋាកបញ្ជាក់។

ប៉ុន្តែជាអកុសល ឪពុករបស់លោកបានទទួលមរណភាពក្នុងឆ្នាំ ២០២២កន្លងទៅនេះ។

រីឯម្តាយរបស់លោកទោះបីមិនសូវចេះនិយាយច្រើន តែគាត់នៅតែលើកទឹកចិត្តដោយអប់រំកូនឱ្យដើរតាមផ្លូវព្រះជាម្ចាស់ ដោយធានារ៉ាប់រងកុំឱ្យខ្វល់ពីក្រុមគ្រួសារ និងសូមឱ្យកូនបម្រើព្រះជាម្ចាស់អស់មួយជីវិត។

ការសិក្សានៅក្នុងទេវវិទ្យាល័យបានជួយដល់ជីវិតខាងផ្លូវវិញ្ញាណរបស់លោក កាន់តែប្រសើរឡើង ហើយជួយលោកឲ្យស្រឡាញ់ជីវិតជាបូជាចារ្យកាន់តែខ្លាំង។

«គ្រាន់តែនឹកដល់ជីវិតជាបូជាចារ្យ ខ្ញុំរំភើបស្ទើរតែហូរទឹកភ្នែកនិយាយលែងចេញ និងមិនដឹងថារៀបរាប់យ៉ាងណាពីអំណរសប្បាយដ៏ពិតប្រាកដនៃជីវិតជាបូជាចារ្យនេះ»។

លោកបន្ថែមថា អំណរសប្បាយរបស់បូជាចារ្យ គឺបាននៅជិតព្រះជាម្ចាស់ «ខ្ញុំមិនមែនធ្វើបូជាចារ្យដើម្បីធ្វើការងារទេ ខ្ញុំចង់ធ្វើជាបូជាចារ្យព្រោះចង់នៅជិតព្រះជាម្ចាស់។

ខ្ញុំនឹងធ្វើការងារដែលព្រះអង្គឱ្យខ្ញុំធ្វើ គឺបម្រើនិងស្រឡាញ់បងប្អូនដែលខ្ញុំនៅជិត។ ស្រឡាញ់បងប្អូនដោយសារព្រះយេស៊ូស្រឡាញ់ខ្ញុំ និងបម្រើបងប្អូនដោយសារព្រះយេស៊ូបម្រើព្រះបិតា ហើយខ្ញុំចង់បម្រើបងប្អូនតាមរបៀបព្រះយេស៊ូ»។

ក្នុងដំណើរជីវិតជានិស្សិតទេវវិទ្យាល័យ គឺមិនងាយស្រួលទេ លោកតែងតែយល់ថាលោកគ្មានសមត្ថភាព ទំនាក់ទំនងខ្សោយ និងប្រៀបធៀបខ្លួនឯងជាមួយអ្នកដទៃ ហើយមើលឃើញលោកីយ៍សម្បូរសប្បាយ បានទាក់ទាញចិត្តរបស់លោកម្តងម្កាល។

លោកបានពោលថា «តែខ្ញុំមិនបានសម្រេចចិត្តភ្លាមៗទេគឺទុកឱ្យព្រះជាម្ចាស់ ព្រះវិញ្ញាណណែនាំ។ [...]ខ្ញុំត្រូវនឹកដល់អ្នកដែលនៅជុំវិញខ្ញុំ រួមទាំងលោកបូជាចារ្យនិងបងស្រី ដែលវត្តមាន។ ពួកគាត់តែងតែលើកទឹកចិត្តធ្វើឱ្យខ្ញុំបន្តដំណើរទៅមុខទៀត។»

ជាមួយគ្នានេះ ពិធីតាំងព្រះកាយព្រះគ្រីស្ត នៅទេវវិទ្យាល័យក្នុងមួយអាទិត្យម្តង បានជួយដល់ជីវិតផ្លូវវិញ្ញាណរបស់លោកកាន់តែខ្លាំង។ « អំឡុងពេលដែលខ្ញុំតាំងព្រះកាយ គឺទទួលបានអំណរសប្បាយនៅក្នុងដួងចិត្តដោយរំភើប»។

លោកបានលើកទឹកចិត្តដល់យុវជនដើម្បីកុំឲ្យខ្លាចទទួលយកការត្រាស់ហៅរបស់ព្រះជាម្ចាស់ជាបូជាចារ្យឬជាអ្នកបួស។ ប្រសិនបើព្រះជាម្ចាស់ត្រាស់ហៅ សូមឆ្លើយតប នោះនឹងមានសុភមង្គលក្នុងចិត្ត។

លោកនិយាយថា «សំខាន់ទី១ យើងត្រូវស្រឡាញ់ព្រះជាម្ចាស់សិន ព្រះអង្គនឹងបំពេញចំណុចខ្វះខាតក្នុងជីវិតរបស់យើង។ យើងទៅបួស គឺយើងនៅ ជាមួយព្រះជាម្ចាស់សិន រីឯការងារ ទេពកោសល្យ សមត្ថភាពយើងនឹងបំពេញតាមហ្នឹង។ ប្រសិនបើយើងខ្វះខាតអី ព្រះសហគមន៍មិនចោលយើងទេ។ សូមក្លាហាននឹងការឆ្លើយតបរបស់ព្រះជាម្ចាស់។»

លោកប៉ូល វិន កាន់ នឹងត្រូវទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យកាតូលិក នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២៣ខាងមុខ នៅមជ្ឈមណ្ឌលភ្នំពេញ ក្រោមអធិបតីភាពរបស់លោកអូលីវីយេ ឆ្មីតហាស្លេ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ៕





# គ្រីស្តបរិស័ទត្រូវផ្តល់សក្ខីភាពពីជំនឿគ្រប់កាលៈទេសៈ

*អត្ថបទ៖ ចាន់ ម៉ានុត*

បេក្ខជនចំនួន១៩នាក់បានសុំចូលព្រះសហគមន៍ (ជំហានទី១) នៅព្រះវិហារសន្តីម៉ារីញញឹមចំការទៀងក្នុងមណ្ឌលសកម្មភាពតាកែវ កាលពីថ្ងៃទី៣ ខែកញ្ញាកន្លងទៅក្រោមអធិបតីភាពរបស់លោកអភិបាល អូលីវីយេ ឆ្មីតហាស្លេ អភិបាលនៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ រួមជាមួយគ្រីស្តបរិស័ទចូលរួមប្រមាណជា៥០នាក់។



តាមកម្មវិធីអប់រំជំនឿរបស់ព្រះសហគមន៍កាតូលិកកម្ពុជា ពិធីជំហានទី១គឺជាជំហានដំបូង ដើម្បីឲ្យអ្នកឈ្វេងយល់ជំនឿប្រកាសអំពីគោលបំណងរបស់ខ្លួន និងសុំចូលរួមជាមួយព្រះសហគមន៍កាតូលិក ដោយប្រកាសដោយផ្ទាល់ខ្លួនថា «ខ្ញុំសូមយកព្រះគ្រីស្តជាទីពឹង ខ្ញុំយកព្រះបន្ទូលជាទីពឹង ខ្ញុំយកព្រះសហគមន៍ជាទីពឹង»។

លោកអភិបាល អូលីវីយេ មានប្រសាសន៍ក្នុងធម្មទេសនាថា កាយវិការរបស់បេក្ខជនម្នាក់ៗ ដែលបានលុតជង្គង់នៅមុខឈើឆ្កាងនិងប្រកាសពាក្យសន្យារបស់ខ្លួន ណែនាំឱ្យយើងនឹកឃើញអំពីជីវិតរបស់យើងជាគ្រីស្តបរិស័ទ ដែលត្រូវផ្តល់សក្ខីភាពគ្រប់ពេលវេលា នៅក្នុងការងារ នៅក្នុងជីវិតគ្រួសារ ជីវិតនយោបាយ ជីវិតដែលយើងរស់នៅសព្វថ្ងៃ។

លោកបានណែនាំឲ្យគ្រីស្តបរិស័ទដែលមានជំនឿយូរហើយ ជួយណែនាំបន្តជំនឿ ឲ្យបេក្ខជនទាំងអស់នៅថ្ងៃនេះយកចិត្តទុកដាក់អធិដ្ឋាននៅស្ងៀមស្ងាត់ជាមួយព្រះជាម្ចាស់ យកពេលវេលានៅក្បែរព្រះកាយព្រះគ្រីស្ត និងយកពេលវេលានៅក្បែរព្រះនាងម៉ារី។

លោកអភិបាលបន្តទៀតថា ពីមួយឆ្នាំទៅមួយឆ្នាំមានអ្នកសុំចូលព្រះសហគមន៍កាតូលិក ចំនួន ៥០-៦០នាក់។ ហើយក្នុងសប្តាហ៍នេះ មានបេក្ខជនចំនួន៩០នាក់ដែលសុំចូលព្រះសហគមន៍ក្នុងមណ្ឌលសកម្មភាពតាកែវ។

លោកអភិបាលសង្កត់ធ្ងន់ថា គឺត្រូវឲ្យប្អូនៗយល់ថា «ពិតមែនខ្ញុំមានទីពឹងថ្មី នៅក្នុងជីវិតធម្មតា ដោយដឹងថាឥឡូវនេះ យើងជាមិត្តសម្លាញ់របស់ព្រះជាម្ចាស់ យើងទាំងអស់ជាមិត្តសម្លាញ់របស់ព្រះជាម្ចាស់ យើងទាំងអស់ជាក្រុមគ្រួសាររបស់ព្រះជាម្ចាស់ដែលជាព្រះបិតា»។

អូលីវីយេ ឆេង វិសាល ក្នុងវ័យ២៣ ឲ្យដឹងថា «ខ្ញុំបានឈ្វេងយល់ជំនឿរយៈពេល២ឆ្នាំមកហើយ ដោយសារមានចិត្តស្រឡាញ់លើព្រះគ្រីស្ត និងចង់ចូលរួមក្នុងព្រះសហគមន៍»។

វិសាល ជាបុគ្គលិកនៃការិយាល័យសិល្បៈរបស់ព្រះសហគមន៍បានបន្តថា ដោយមើលឃើញអំពីសកម្មភាពរបស់ព្រះសហគមន៍ ដូចជាការជួយសង្គ្រោះ ការជួយអ្នកក្រីក្រ អ្នកជំងឺ និងសកម្មភាពផ្សេងៗមានទាំងការងារសិល្បៈ ជាមួយយុវជន ជំទង់និងកុមារ ធ្វើឲ្យគាត់ចាប់អារម្មណ៍ចង់ស្គាល់ព្រះយេស៊ូ។

ជាមួយគ្នានេះ វេរ៉ូនីកា ណារី សព្វថ្ងៃរៀនថ្នាក់ទី៦ នៅសាលាបឋមសិក្សាសន្តហ្វ្រង់ស័រក្នុងភូមិចំការទៀងនិយាយថា បានជានាងសុំចូលព្រះសហគមន៍(ជំហានទី)ដោយសារចង់ស្គាល់ព្រះគ្រីស្ត ចង់ដើរតាមព្រះយេស៊ូ និងចង់ក្លាយជាគ្រីស្តបរិស័ទ។

នាងបន្តថា ឪពុកម្តាយមិនបានរារាំងឬស្តីបន្ទោសឱ្យនាងឡើយ តែបែរជាជំរុញនិងលើកទឹកចិត្តឱ្យនាងខិតខំថែរក្សាសេចក្តីស្រលាញ់ចំពោះព្រះសហគមន៍ និងចូលរួមសកម្មភាពជាមួយព្រះសហគមន៍ឱ្យកាន់តែសកម្មជាងនេះទៀត។

កុមារីរូបនេះ បានបញ្ជាក់ថា នាងនឹងខិតខំថែរក្សាសេចក្តីស្រលាញ់ ដោយយកព្រះគ្រីស្តជាទីពឹង យកព្រះបន្ទូលជាទីពឹង យកព្រះសហគមន៍ជាទីពឹង នឹងព្យាយាមសិក្សាឈ្វេងយល់បន្ថែមទៀតអំពីជំនឿ។

លោក កុល ជាង ជាគ្រូអប់រំជំនឿនិងជាប្រធានព្រះសហគមន៍សន្តីម៉ារីញញឹមចំការទៀង មានប្រសាសន៍ថា ដោយមើលឃើញសកម្មភាពយ៉ាងសកម្មរបស់បេក្ខជនទាំង១៩នាក់ ជាមួយនឹងការចូលរួមថ្វាយអភិបូជា សកម្មភាពសង្គហៈ សកម្មភាពយុវជន ការអប់រំជំនឿប្រចាំសប្តាហ៍ព្រះសហគមន៍ បានសម្រេចឱ្យបេក្ខជនទាំងអស់ធ្វើពិធីសុំចូលព្រះសហគមន៍(ជំហានទី១)។

តាមការបញ្ជាក់របស់លោក កុល ជាង បានឱ្យដឹងថា បេក្ខជនទាំង១៩នាក់ មកពីព្រះសហគមន៍ចំនួន២ គឺ ព្រះសហគមន៍សន្តីម៉ារីញញឹមចំការទៀង និងព្រះសហគមន៍ត្រពាំងក្រញូង។ មណ្ឌលកម្មភាពនេះ មានព្រះសហគមន៍ចំនួន៨ គឺចំការទៀង គីរីវង់ ព្រៃកប្បាស សន្តប៉ូល បាទី កំពង់អំពិល ត្រពាំងគ្រញូង និងក្រុងតាកែវ៕

# លោក ប៊ុន លី៖ បូជាចារ្យជាស្ពានសម្រាប់ព្រះជាម្ចាស់និងមនុស្ស

*អត្ថបទ៖ ស៊ីអេសស៊ី*

លោកថៃរតនៈ ហៅប៊ុនលី ជាឧបដ្ឋាកបម្រើការងារនៅព្រះវិហារសន្តយ៉ូសែបផ្សារតូច បានឲ្យដឹងថាតាំងពីតូចមកលោកចាប់អារម្មណ៍ ចង់ក្លាយជាបូជាចារ្យដោយមានសញ្ញាមួយចំនួន។

លោកប៊ុនលីនិយាយថា «លោកបូជាចារ្យមានគំរូពិសេស ទី១មិនមានគ្រួសារ គាត់បានយកចិត្តទុកដាក់ ខាងវិញ្ញាណរបស់គ្រីស្តបរិស័ទ គាត់បានលះបង់ជីវិតដើម្បីបម្រើអ្នកដទៃ ជាហេតុខ្ញុំចង់ក្លាយជាបូជាចារ្យដែរ។ »

បច្ចុប្បន្ននេះ លោក ថៃ រតនៈ ហៅ ប៊ុនលី កំពុងបម្រើការងារនៅមណ្ឌលសកម្មភាពភ្នំពេញខាងជើង ក្រោមការណែនាំរបស់លោកបូជាចារ្យប៉ូលរឿងឆ័ត្រសិរី។ មណ្ឌលសកម្មភាពនេះ មានព្រះសហគមន៍ចំនួន៨ ស្ថិតនៅភាគខាងជើងរាជធានីភ្នំពេញ។ លោកបានចូលរួមសកម្មភាពជាមួយកុមាររហូតដល់ចាស់ជរា និងបានចូលរួមជាមួយគណៈកម្មការនានារបស់ព្រះសហគមន៍ក្នុងគោលដៅប្រកាសដំណឹងល្អដោយការបម្រើ។

ក្នុងមុខងារជាឧបដ្ឋាកព្រះសហគមន៍ លោកបានយកចិត្តទុកដាក់ចែកព្រះកាយនៅតាមផ្ទះដែលមានគ្រីស្តបរិស័ទចាស់ជរា និងមានជំងឺ ចុះសួរសុខទុក្ខព្រះសហគមន៍ក្នុងតំបន់ អធិដ្ឋានជាមួយបូជាចារ្យទទួលខុសត្រូវ និងចូលរួមថ្វាយអភិបូជាប្រចាំថ្ងៃ។

លោកបានខិតខំធ្វើយ៉ាងណាដើម្បីឲ្យជីវិតខាងផ្លូវវិញ្ញាណរីកចម្រើនឡើង ដោយទទួលការណែនាំពីលោកបូជាចារ្យប្រធានព្រះសហគមន៍ និងខិតខំអធិដ្ឋានជាប្រចាំ។

លោកប៊ុនលីឲ្យដឹងទៀតថា «លោកបូជាចារ្យជាគំរូសម្រាប់មនុស្សទាំងអស់ ហើយលោកបូជាចារ្យដូចជាបុគ្គលម្នាក់សំខាន់សម្រាប់ព្រះជាម្ចាស់ គឺជាស្ពានសម្រាប់ព្រះជាម្ចាស់និងមនុស្សដែរ។»

លោកឧបដ្ឋាក អន់តូនី ថៃ រតនៈ ហៅ ប៊ុនលី កើតនៅថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ១៩៩៣ នៅភូមិលូ សង្កាត់ស្វាយប៉ាក ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។ លោកស្ថិតក្នុងគ្រួសារគ្រីស្តបរិស័ទកាតូលិក ជាកូនទី២ ក្នុងចំណោមបងប្អូនប្រុសស្រីចំនួន៤នាក់។

ការត្រាស់ហៅជាបូជាចារ្យកើតមានឡើងនៅក្នុងវ័យកុមារ ខណៈពេលដែលលោកបានចូលរួមជារៀងរាល់ថ្ងៃក្នុងក្រុមកុមារបម្រើអាសនៈពេលថ្វាយអភិបូជា ហើយគំរូរបស់លោកបូជាចារ្យ និងគ្រូអប់រំជំនឿបានជួយណែនាំលោកឱ្យឈ្វេងយល់ពីការត្រាស់ហៅជាបូជាចារ្យនេះដែរ។ តែទោះបីជាយ៉ាងណា កត្តាជីវភាពគ្រួសារនិងការសិក្សាជាឧបសគ្គមួយ ដោយតម្រូវឲ្យកុមារប៊ុនលីស្វះស្វែងរកគ្រប់មធ្យោបាយ បន្តការសិក្សានៅកម្រិតមធ្យម ដើម្បីអាចបន្តចូលទេវវិទ្យាល័យបាន។

ក្នុងឆ្នាំ២០០៧ ដល់២០១១ កុមារប៊ុនលី បានទៅសិក្សានិងរស់នៅក្នុងសាលាដុនបូស្កូផ្នែកបុរស ដោយរៀនចំណេះទូទៅផង រៀនអធិដ្ឋានផង និងរៀនរស់នៅជាក្រុមជាមួយកុមារនិងយុវជនដទៃ ដែលធ្វើឲ្យបំណងដែលចង់បួសលេចចេញមកកាន់តែខ្លាំងឡើងៗ។

ដោយមានការគាំទ្រពីឪពុកម្តាយ និងជាពិសេសលោកយាយរបស់លោក ក្រោយចប់មធ្យមសិក្សា លោកបានសម្រេចចិត្តចូលទេវវិទ្យាល័យ ក្នុង២០១៥។ បីឆ្នាំក្រោយមកលោកទទួលមុខងារជានិស្សិតទេវវិទ្យាល័យផ្លូវការ ហើយបានទទួលមុខងារជាបន្តបន្ទាប់ ដូចជាមុខងារប្រកាសព្រះបន្ទូលក្នុងឆ្នាំ២០១៩ និងមុខងារបម្រើតុសក្ការៈក្នុងឆ្នាំ២០២១ រហូតដល់ទទួលអគ្គសញ្ញាតែងតាំងជាឧបដ្ឋាកនាថ្ងៃទី១០ កញ្ញា២០២២។ ហើយនៅថ្ងៃទី២៣ ខែកញ្ញានេះ លោកនឹងទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យកាតូលិកនៅមជ្ឈមណ្ឌលភ្នំពេញថ្មី រួមជាមួយលោកឧបដ្ឋាក២រូបទៀត ក្រោមអធិបតីរបស់លោក អភិបាលព្រះសហគមន៍ភូមិភាគភ្នំពេញ អូលីវីយេ ឆ្មីតហាស្លេ។



លោកឧបដ្ឋាកបានប្រាប់ថា តាមរយៈការអធិដ្ឋានមានទំនាក់ទំនងជាមួយព្រះជាម្ចាស់ និងបទពិសោធន៍អំពីសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ដែលមានដល់រូបលោកផ្ទាល់ លោកបានរកឃើញការត្រាស់ហៅជាជីវិតអ្នកបួស។

លោកបានលើកទឹកចិត្តយុវជនទាំងអស់កុំឲ្យភ័យខ្លាចឆ្លើយតបនឹងការត្រាស់ហៅជាអ្នកបួស «កុំខ្លាចអ្វី! សូមទៅមុខ! បញ្ហាផ្សេងៗវានឹងកើតឡើង តែព្រះជាម្ចាស់មានដំណោះស្រាយសម្រាប់យើង។ សូមកុំខ្លាចអ្វី! បន្តទៅមុខស្វែងរកការត្រាស់របស់ព្រះជាម្ចាស់ ក៏កុំភ្លេចអធិដ្ឋានឱ្យច្រើន ដើម្បីមានទំនាក់ទំនងល្អជាមួយព្រះយេស៊ូ ដោយសារតាមរយៈការទំនាក់ទំនងការអធិដ្ឋាននោះហើយ នាំឱ្យយើងអាចស្គាល់ការត្រាស់ហៅរបស់ព្រះជាម្ចាស់ចំពោះខ្លួនឯង។»

# សកម្មភាពនានារបស់ព្រះសហគមន៍កាតូលិកកម្ពុជា

## ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ



## ព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង



## ព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម

